## នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jun-2015, 08:30
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (កោសលុប)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាតុលាការកំពូល **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើទីប្រាំរបស់ នួន ជា សុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែម ពាក់ព័ន្ធ បណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
Doreen CHEN
Xiaoyang NIE
Marina HAKKOU

**ចម្លងជូន÷**

**សហមេធាវីការពារក្តី ខៀវ សំផន÷**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី÷**

ពេជ អង្គ
Marie GUIRAUD

អនុលោមតាមវិធាន ១០៤(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីលោក នួន ជា (“មេធាវី

ការពារក្តី") សូមដាក់សំណើនេះ ("សំណើ") សុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែម ពាក់ព័ន្ធបណ្តឹងសាទុក្ខរបស់ខ្លួន ប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ("បណ្តឹងសាទុក្ខ")[1]។

## I. សាវតារ និងប្រវត្តិនីតិវិធី

### ក. ការសម្រេចរបស់អង្គជំនុំជម្រះ និងការប្តឹងសាទុក្ខរបស់មេធាវីការពារក្តី និងទឡ្ហីករណ៍ក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល ស្តីពីរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា និងតួនាទីរបស់ភូមិភាគ

1. នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ដែលបានប្រកាសកាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សាលក្រម") អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា រចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជាមាន "ឋានានុក្រម" និង "ជាពីរ៉ាមីត" ហើយកម្មាភិបាលនៅក្នុងបក្សស្ថិតនៅក្រោម "ថ្នាក់ដឹកនាំបក្ស"[2]។ លើសពីនេះទៀត សាលក្រមបានសម្រេចថា "មេដឹកនាំភូមិភាគ" ដូចជា សោ ភឹម និងរស់ ញឹម បានអនុវត្តតាមយ៉ាងស្មោះត្រង់ នូវការណែនាំរបស់ "ថ្នាក់ដឹកនាំ" បក្ស ហើយបាន "រាយការណ៍ជូន" ប៉ុល ពត និងនួន ជា និងទទួលការណែនាំពីប៉ុល ពត និងនួន ជា[3]។ អង្គជំនុំជម្រះបានច្រានចោលលទ្ធភាពដែលថា "មេដឹកនាំភូមិភាគ" ទាំងនេះ បានធ្វើសកម្មភាពដោយឯករាជ្យ ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់។ តែផ្ទុយមកវិញ អង្គជំនុំជម្រះបានផ្តន្ទាទោសនួន ជា ពីបទឧក្រិដ្ឋទាំងអស់ដែលត្រូវបានចោទប្រកាន់ រួមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើមនុស្សឃាត និងការសម្លាប់អតីតអ្នករដ្ឋការ និងយោធារបបសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃ ក្នុងភូមិភាគពាយ័ព្យ ហើយបានកំណត់ទោសដាក់ពន្ធនាគារអស់មួយជីវិត។

2. មេធាវីការពារក្តីបានជំទាស់ទៅលើការសម្រេចទាំងនេះ ដោយផ្អែកទៅលើមូលដ្ឋានបណ្តឹងសាទុក្ខមួយចំនួន នៅក្នុងបណ្តឹងសាទុក្ខចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ របស់ខ្លួន។ មូលដ្ឋានទាំងអស់នេះបានអះអាងសាជាថ្មី ហើយបានបង្កើតឡើងដោយផ្អែកលើទឡ្ហីករណ៍កន្លងមក ដែលខ្លួនបាន

---

[1] ឯកសារ F16, 'បណ្តឹងសាទុក្ខរបស់នួន ជា ប្រឆាំងសាលក្រមសំណុំរឿង ០០២/០១', ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ("បណ្តឹងសាទុក្ខ").

[2] ឯកសារ E313, 'សាលក្រមសំណុំរឿង ០០២/០១', ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សាលក្រម"), កថាខណ្ឌ ២២៣ និង ៩១៣។

[3] សូមមើល ជាឧទាហរណ៍ ឯកសារ E313, សាលក្រម, កថាខណ្ឌ ២៧៦, ៧៧៣, ៧៩៨, ៨៥១, ៨៩៣ និង ៩៥៦។

ធ្វើឡើងក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០១ ("សារណាបញ្ចប់ការពិភាក្សាដេញដោល")[4] ហើយដែលអង្គជំនុំជម្រះសាលាដំបូងបានបំភ្លេចយ៉ាងកងរំពង នៅក្នុងសាលក្រមរបស់ខ្លួន។ ចំណុចសំខាន់ៗដែលភាគីការពារក្តីបានលើកឡើងគឺថា "មជ្ឈិមបក្ស" នៅក្នុងទីក្រុងភ្នំពេញ បានប្រើប្រាស់តែត្រឹមការត្រួតត្រាប្រកបដោយប្រសិទ្ធភាព ក្នុងកម្រិតកំណត់មួយ ទៅលើកម្មាភិបាលនានា នៅក្នុងឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា[5]។ ជាជាងការមាន "ឋានានុក្រម" និង "ជាតីរ៉ាមីត" បក្សកុម្មុយនីស្តកម្ពុជាបានបែកបាក់ ដោយមានការបែងចែកជាបក្សពួកយ៉ាងជ្រាលជ្រៅ ហើយពុកផុយដោយសារជម្លោះប្រដាប់អាវុធដែលធ្វើឲ្យខូចខាតទៅវិញទៅមក។ "មេដឹកនាំភូមិភាគ" ដូចជាសោ ភឹម និងរស់ ញឹម មិនស្ថិតនៅក្រោមប៉ុល ពត និងនួន ជានោះទេ ប៉ុន្តែពួកគេគឺជាមេដឹកនាំដែលមានអំណាច ដែលប្រើប្រាស់សិទ្ធិអំណាចដោយឯករាជ្យយ៉ាងខ្លាំងក្លា ដែលប៉ុល ពត, នួន ជា និងអ្នកដទៃទៀត មិនអាចធ្វើអន្តរាគមន៍បាន សូម្បីតែបន្តិច បន្តួចក៏ដោយ។ សោ ភឹម, រស់ ញឹម និងអ្នកដទៃទៀត ដូចជា កុយ ធួន បានបង្កើនសិទ្ធិអំណាចរបស់ពួកគេ ចាប់តាំងពីក្រោយពេលរំដោះភ្លាមៗ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដើម្បីបង្កការបះបោរប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្របច្បាប់។ ការប្រឆាំងនេះត្រូវបានគាំទ្រយ៉ាងខ្លាំងក្លាដោយវៀតណាម ហើយបក្សនេះត្រូវបានគាំទ្រពីក្រោយដោយសហភាពសូវៀត។ ហើយវៀតណាមរួមពាក់ព័ន្ធនឹងសម្ព័ន្ធភាពរវាង សោ ភឹម, រស់ ញឹម កុយ ធួន វ៉ន វ៉េត និងអ្នកដទៃជាច្រើនទៀត នៅក្នុងគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមរបស់បក្សកុម្មុយនិស្ត។ ជាការពិតតួនាទីរបស់វៀតណាម និងសហភាពសូវៀតទាក់ទងនឹងការបះបោល និង/ឬផែនការក្បត់ នឹងត្រូវបានពិភាក្សាពិស្តានៅក្នុងសំណើទី៦ សុំភស្តុតាងបន្ថែម។

## ខ. ការបែកខ្ញែកភស្តុតាងទាក់ទងនឹងសំណុំរឿង ០០២/០១ នៅក្នុងសំណុំរឿង អវតក

3. ភស្តុតាងសំខាន់ៗទាក់ទងនឹងសំណុំរឿង ០០២/០១ បានទៅដល់ការស៊ើបអង្កេតសំណុំរឿង ០០៣ និង ០០៤។ នៅក្នុងសំណុំរឿង ០០២/០១ មេធាវីការពារក្តីបានទទួលកំណត់ហេតុស្តាប់ចម្លើយបន្តិចម្តងៗ ដែលត្រូវបានបើកបង្ហាញ ដោយការយកចេញពីសំណុំរឿង ០០៣ និង០០៤ ជូនដល់មេធាវីការពារក្តី រួមទាំងកំណត់ហេតុស្តាប់ចម្លើយខ្លះ ដែលត្រូវបានបញ្ចេញត្រឹមតែ ៧២

---

[4] ឯកសារ E295/6/3, 'សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់នួន ជា ក្នុងសំណុំរឿង ០០២/០១', ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ("សារណាបញ្ចប់ការពិភាក្សាដេញដោល"), កថាខណ្ឌ ១៨០ ដល់១៨៧ និង ៤៣៥ ដល់៤៣៧, ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល, ឯកសារ E1/232.1), ទំព័រ ២៣ ដល់២៥។

[5] ឯកសារ F16, បណ្តឹងសាទុក្ខ, កថាខណ្ឌ ២២៥, ២៣០ និង ២៣៦ ដល់២៤៣។

ម៉ោង មុនកាលបរិច្ឆេទកំណត់ ដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល។ នៅក្នុងសំណុំរឿង ០០២/០២ ការដាក់បង្ហាញនេះបានកើនយ៉ាងគំហុកដូចជាទឹកជំនន់។ ចាប់តាំងពីខែ វិច្ឆិកា ឆ្នាំ ២០១៤ មេធាវីការពារក្ដី បានទទួលឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ដូចទឹកបាក់ទំនប់មកពីសំណុំរឿង ០០៣ និង០០៤។ មេធាវីការពារក្ដីបានព្យាយាមពិនិត្យមើលលើឯកសារទាំងអស់នេះ ឲ្យបានឆាប់រហ័សបំផុត តាមលទ្ធភាពដែលខ្លួនអាចធ្វើបាន ដើម្បីកំណត់ទៅលើកំណត់ហេតុស្ដាប់ចម្លើយទាំងអស់ ដែលអាចមានភាពពាក់ព័ន្ធដល់បណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១។ ប៉ុន្តែការនេះបានបង្ហាញថា វាជាភារកិច្ចដ៏លំបាកបំផុត ក្នុងការសម្រេចឲ្យបាន។ កាលវិភាគសវនាការដែលមិនមានការបន្ធូរបន្ថយ នៅក្នុងសំណុំរឿង ០០២/០២ បានដាក់បន្ទុករួចទៅហើយ នូវបន្ទុកការងារដែលធំជាងបន្ទុកការងារពេញម៉ោងទៅទៀត មកលើមេធាវីការពារក្ដី និងកម្រិតពេលយ៉ាងខ្លាំងសម្រាប់ពេលវេលាគ្រប់គ្រាន់សម្រាប់មេធាវីការពារក្ដីក្នុងការប្រឹក្សាជាមួយកូនក្ដី។ ផលប៉ះពាល់នៃកាលវិភាគសំណុំរឿង ០០២/០២ ធ្វើឲ្យកាន់តែធ្ងន់ទៅលើធនធានមានកំណត់របស់មេធាវីការពារក្ដី ដោយសារតែការិយាល័យរដ្ឋបាលនៅតែស្ទាក់ស្ទើរក្នុងការផ្ដល់ធនធានបន្ថែម និងសេចក្ដីត្រូវការសម្រាប់មេធាវីការពារក្ដីក្នុងការបំពេញការងារបន្ថែមទាក់ទងនិងបណ្ដឹងឧទ្ធរណ៍។ ជាងនេះទៅទៀតទំហំឯកសារថ្មីរបស់សហព្រះរាជអាជ្ញាដែលបានដាក់បង្ហាញគឺមានចំនួនច្រើន។ លើសពីនេះទៀត មេធាវីការពារក្ដីបានទទួលរួចហើយនូវភស្តុតាងដែលបានផ្ដល់ឲ្យចំនួន៤១៦នាក់ ដែលពួកគេភាគច្រើនមិនដែលត្រូវបានស្ដាប់ចម្លើយនៅក្នុងសំណុំរឿង ០០២ ដែលធ្វើឲ្យកើនឡើងនូវភស្តុតាងដល់ ៧.៦៣៤ ទំព័រ (ជាភាសាអង់គ្លេស)។ ជិតមួយភាគប្រាំនៃភស្តុតាងថ្មី (១.៣៤៧ទំព័រ) ទើបត្រូវបានដាក់បង្ហាញជូនមេធាវីការពារក្ដី នៅថ្ងៃទី ០៩ និងទី ១១ ខែ មិថុនា ឆ្នាំ ២០១៥ នេះតែប៉ុណ្ណោះ។

4. ដោយយោងទៅលើទំហំនៃឯកសារដែលបានដាក់បង្ហាញ ព្រមទាំងធនធានបន្តិចបន្តួច និងបន្ទុកការងារដ៏ធ្ងន់ធ្ងរបំផុតរបស់មេធាវីការពារក្ដី ហើយនឹងលក្ខខណ្ឌរឹតបណ្ដឹងដែលបានដាក់ចំពោះមេធាវីការពារក្ដី ពាក់ព័ន្ធនឹងឯកសារទាំងនេះ ទើបក្នុងពេលកន្លងមកនេះ មេធាវីការពារក្ដីត្រឹមតែអាចពិនិត្យដោយត្រួសៗ ទៅលើឯកសារដែលបានដាក់បង្ហាញទាំងអស់ប៉ុណ្ណោះ។ មេធាវីការពារក្ដីបានដាក់ជូនរួចហើយនូវកំណត់ហេតុស្ដាប់ចម្លើយដ៏សំខាន់មួយ នៅក្នុងសំណើសុំដាក់ភស្តុតាងបន្ថែមទីបីរបស់ខ្លួន ("សំណើសុំភស្តុតាងបន្ថែមលើកទីបី") ហើយបានស្នើសុំឲ្យសាក្សី

ដែលពាក់ព័ន្ធ គឺសាក្សី SCW-5 ឲ្យមកផ្តល់សក្ខីកម្ម[6]។ នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកកំណត់ហេតុស្តាប់ចម្លើយ ហើយបានកំណត់កាលបរិច្ឆេទសម្រាប់សាក្សី SCW-5 មកផ្តល់សក្ខីកម្មនៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥[7]។ សំណើក្នុងពេលនេះពាក់ព័ន្ធដោយផ្នែកនឹងកំណត់ហេតុស្តាប់ចម្លើយ បន្ថែមទៀតចំនួនប្រាំ និង ឧបសម្ព័ន្ធមួយ ដែលមេធាវីការពារក្តីអាចកំណត់អត្តសញ្ញាណបានកំណត់ហេតុស្តាប់ចម្លើយដែលដាក់បង្ហាញនោះ ហើយដែលភ័ស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយទាំងនោះ ពាក់ព័ន្ធនឹងចំណុចដ៏សំខាន់នៃសក្ខីកម្មរបស់សាក្សី SCW-5 ព្រមទាំងចំណុចគន្លឹះនៃការការពារក្តី ដូចដែលបានសង្ខេបនៅផ្នែកខាងលើ។ សំណើបន្ថែមនឹងប្រហែលជាមានជាបន្តបន្ទាប់ យ៉ាងហោចណាស់រហូតដល់ចុងបញ្ចប់នៃសវនាការលើបណ្តឹងសាទុក្ខ សំណុំរឿង ០០២/០១[8] ដោយសារតែការត្រួតពិនិត្យរបស់មេធាវីការពារក្តី ទៅលើឯកសារដែលបានដាក់បង្ហាញ ព្រមទាំងកិច្ចស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលកំពុងបន្ត។ តាមពិតទៅមេធាវីការពារក្តីអាចបន្តទទួលបានភ័ស្តុតាង ដែលមានសារសំខាន់ចំពោះសំណុំរឿង ០០២/០១ នៅក្រោយសវនាការលើបណ្តឹងសាទុក្ខ ដែលមេធាវីការពារក្តីប្រហែលមិនអាចដាក់ជូន នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ព្រោះកិច្ចស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ ប្រហែលជាបន្តរហូតដល់ក្រោយពេលបញ្ចប់ សវនាការលើបណ្តឹងសាទុក្ខ។ នៅដំណាក់កាលនេះ ការស៊ើបអង្កេតទាំងអស់ត្រូវបានគេរំពឹងថានឹងបន្តរហូតដល់ដំណាច់ឆ្នាំ ២០១៥ សម្រាប់សំណុំរឿង ០០៣ និងរហូតដល់ដំណាច់ឆ្នាំ ២០១៥ដូចគ្នា ឬដល់ត្រីមាសទីមួយឆ្នាំ ២០១៦ សម្រាប់សំណុំរឿង ០០៤ (អាស្រ័យលើថាតើ

---

[6] ឯកសារ **F2/4**, 'សំណើលើកទីបី សុំឲ្យពិចារណា និងទទួលយកភ័ស្តុតាងបន្ថែម ទាក់ទងជាមួយបណ្តឹងសាទុក្ខប្រឆាំងសាលក្រម ក្នុងសំណុំរឿង ០០២/០១', ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("សំណើសុំលើកទីបី លើភ័ស្តុតាងបន្ថែម")។

[7] ឯកសារ **F2/5**, 'សេចក្តីសម្រេចលើសំណើរបស់នួន ជា មួយផ្នែក សុំឲ្យកោះហៅសាក្សីបណ្តឹងសាទុក្ខ ', ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើកទីមួយ របស់អង្គជំនុំជម្រះតុលាការកំពូលចំពោះសាក្សី"), កថាខណ្ឌ ២៦។ ឯកសារ **F24**, 'ដីកាកំណត់កាលបរិច្ឆេទសវនាការ', ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥, ERN 01102026 និងឯកសារ **F24.1**, 'ឧបសម្ព័ន្ធ– កាលវិភាគសម្រាប់សវនាការ', ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥, ERN 01102027។

[8] វិធាន ៩២ នៃវិធានផ្ទៃក្នុង។ ឯកសារ **F2/5**, សេចក្តីសម្រេចលើកទីមួយ របស់អង្គជំនុំជម្រះតុលាការកំពូលចំពោះសាក្សី, កថាខណ្ឌ ២៤។

សំណុំរឿង ០០៤ ត្រូវបានបំបែកកិច្ចដំណើរការនីតិវិធី ឬអត់)[9]។

5. បន្ថែមពីលើនេះការជាន់គ្នារវាងសំណុំរឿង ០០២/០១ និង ០០២/០២ មានន័យថា ភស្តុតាងដែលពាក់ព័ន្ធក្នុងសំណុំរឿងបណ្តឹងសាទុក្ខ នឹងរួមបញ្ចូលគ្នាជាយថាហេតុនៅក្នុងដំណើរការសំណុំរឿង ០០២/០២។ ហើយវាបានកើតឡើងមានមែន។ មេធាវីការពារក្តីបានដាក់នូវសំណើបន្ថែមលើកទី៤ ឱ្យទទួលយកប្រតិចារិក នៃសក្ខីកម្មរបស់ ពេជ្រ ជឹម នៅក្នុងសវនាការសំណុំរឿង ០០២/០២[10]។ បន្ថែមពីលើនេះ សំណើលើកទី៦សុំភស្តុតាងបន្ថែមក្នុងចំណោមនោះទាក់ទងភស្តុតាងអំពីការបះបោល និងរដ្ឋប្រហារនៅភូមិភាគឧត្តរ និងតំបន់ ១០៦ ទាក់ទងនឹងកងទ័ពបដិវត្តកម្ពុជាកងពល ១៧០ ៣១០ ៤៥០ និង ៩២០។

## គ. ភស្តុតាងរបស់សាក្សី SCW-5 និងសារសំខាន់នៃភស្តុតាងនេះ ចំពោះបណ្តឹងសាទុក្ខ

6. ដូចដែលបានបញ្ជាក់ពីខាងលើ កំណត់ហេតុស្តាប់ចម្លើយដែលបង្កើតជាកម្មវត្ថុនៃសំណើនេះ គឺមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការការពារក្តី និងចំពោះសក្ខីកម្មដែលរំពឹងទុក របស់សាក្សី SCW-5 នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។ សក្ខីកម្មដែលអាចផ្តល់ដោយសាក្សី SCW-5 និងសារសំខាន់នៃសក្ខីកម្មនេះ ត្រូវបានរៀបរាប់ដោយលម្អិតនៅក្នុង សំណើទីបីសុំឱ្យទទួលយកភស្តុតាងរបស់មេធាវីការពារក្តី ("សំណើទីបីសុំឱ្យទទួលយកភស្តុតាង")[11]។ ទោះជាយ៉ាងនេះក្តី មេធាវីការពារក្តី សូមសង្ខេបខ្លឹមសារពីសំណើទីបី ដើម្បីភាពងាយស្រួល។

7. [redacted]

---

[9] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, 'ផែនការបញ្ចប់៖ វិសោធនកម្មលើកទីបួន', ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥, កថាខណ្ឌ ៣០, អាចរកបាននៅ http://www.eccc.gov.kh/sites/default/files/Completion%20plan%20Rev%204%20Final.pdf។

[10] **F2/6** "សំណើលើកទី៤របស់ នួន ជា សូមឱ្យពិចារណាក្នុងការទទួលយកភស្តុតាងបន្ថែមសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥។

[11] សូមមើល, ឯកសារ **F2/4**, សំណើលើកទីបី លើភស្តុតាងបន្ថែម, កថាខណ្ឌ ៧ ដល់១១ និង ១៥ ដល់២២។

[12] [redacted]។

[redacted]។ កំណត់ហេតុស្តាប់ចម្លើយរបស់គាត់បង្ហាញពីការដឹងឮយ៉ាងទូលំទូលាយរបស់គាត់ អំពីបុគ្គលិករចនាសម្ព័ន្ធបញ្ជាការ និងហេតុការណ៍នៅក្នុងភូមិភាគពាយ័ព្យ រួមទាំងការចោទប្រកាន់ពីការសម្លាប់អតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃ។ នៅខែ មេសា ឆ្នាំ ១៩៧៨ សាក្សី SCW-5 បានដកខ្លួនចូលទៅក្នុងព្រៃ ក្នុងពេលមានការចាប់ខ្លួននៅភូមិភាគពាយ័ព្យ និងបូព៌ា ហើយនៅពេលក្រោយមកបានដឹកនាំកងទ័ព ២០០០នាក់ ចូលទៅក្នុងព្រៃ និងបានបញ្ជាកងទ័ពទាំងនោះ វាយប្រយុទ្ធជាមួយកងទ័ពភូមិភាគនិរតី ក្នុងឆ្នាំ ១៩៧៨។ កងទ័ពដែលសាក្សី SCW-5 ដឹកនាំបានប្រើប្រាស់អាវុធចំនួន ២០.០០០ដើម ដែលគាត់បានប្រមូលក្នុងពេលកន្លងមកពីទាហាន លន់ នល់។ បន្ទាប់ពីមាន "ការចាប់ខ្លួនសោ ភឹម នៅខែ ឧសភា ឆ្នាំ ១៩៧៨" សាក្សី SCW-5 បានផ្តល់ដល់ រស់ ញឹម នូវ [redacted] បន្ទាប់ពីទទួលបានការស្នើសុំពី រស់ ញឹម។ សាក្សី SCW-5 បានអះអាងថាគាត់បានបង្កើតក្រុមមួយ ប្រឆាំងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ នៅពេលមួយក្នុងឆ្នាំ ១៩៧៨ ដោយគ្រប់គ្រងលើតំបន់ចំនួនប្រាំពីរក្នុងភូមិភាគពាយ័ព្យ ហើយនៅពេលមួយគាត់បានទាក់ទង និងសម្របសម្រួលជាមួយកងទ័ពភូមិភាគបូព៌ារបស់ ហេង សំរិន។

8. សាក្សី SCW-5 គឺអាចជាសាក្សីដ៏សំខាន់មួយរូប ពាក់ព័ន្ធនឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃ។ គាត់មានទំនាក់ទំនងផ្ទាល់ខ្លួន និងទំនាក់ទំនងការងារជិតស្និទ្ធិខ្លាំងជាមួយ រស់ ញឹម។ គាត់ប្រហែលជាសាក្សីតែម្នាក់ដែលដឹងប្រាកដថាតើ រស់ ញឹម បញ្ជាឲ្យសម្លាប់យោធា និងអ្នករដ្ឋការនៅទួលពោធិ៍ជ្រៃដែរ ឬអត់ ហើយប្រសិនបើដូច្នេះ តើបញ្ជានេះត្រូវបានធ្វើឡើងនៅពេលណា ហើយតើបញ្ជានេះត្រូវបានផ្សព្វផ្សាយដោយរបៀបណា តើបញ្ជានេះមានវិសាលភាពត្រឹមណា និងសំខាន់បំផុតនោះថាតើបញ្ជានេះត្រូវបានចេញពីគណកម្មាធិការអចិន្ត្រៃយ៍ នៃបក្សកុម្មុយនីស្តកម្ពុជា ឬពីនួន ជា និងប៉ុល ពត ហើយតើក្នុងកម្រិតណាដែរ។ សក្ខីកម្មដែលអាចជឿជាក់បានរបស់សាក្សី SCW-5 ចំពោះបញ្ហាទាំងអស់នេះ នឹងលប់ពីលើតម្លៃនៃភស្តុតាងរបស់ភស្តុតាងដែលមានរួចហើយនៅលើកំណត់ត្រា។

9. សាក្សី SCW-5 ក៏ជាសាក្សីដ៏សំខាន់មួយរូបផងដែរ ពាក់ព័ន្ធរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា និងប្រភពដើម វិសាលភាព ព្រមទាំងលក្ខណៈនៃជម្លោះប្រដាប់អាវុធ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយសក្ខីកម្មរបស់គាត់បានគាំទ្រ ដល់សារណារបស់មេធាវីការពារក្តីដែលថា ថ្នាក់ដឹកនាំនៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា បានបង្កើតបក្សប្រឆាំងរួមគ្នាមួយ ប្រឆាំងបក្សកុម្មុយនី

ស្តកម្ពុជាចាប់តាំងពីដើមឆ្នាំ ១៩៧៦ និងប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ[13] ដែល សោ ភឹម និង រស់ ញឹម បានបម្រើក្នុងឋានជាមន្ត្រីជាន់ខ្ពស់[14]។ សាក្សី SCW-5 បានរៀបរាប់ថា ខ្លួនគាត់ផ្ទាល់បានបណ្តុះគ្រាប់ពូជ នៃជម្លោះប្រដាប់អាវុធដោយចំហរនេះ តាំងពីឆ្នាំ ១៩៧៥ មកម្ល៉េះ។ ដោយសារតែតួនាទីរបស់គាត់នៅក្នុង

---

[13] យោងតាមរដ្ឋាភិបាលហូឡង់ កម្ពុជាប្រជាធិបតេយ្យមានទំនាក់ទំនងជាផ្លូវការជាមួយប្រទេសជាច្រើននៅក្នុងសហគមន៍អឺរ៉ុប រួមមានប្រទេស ហូឡង់ ដែណឺម៉ាក អ៊ីតាលី ចក្រភពអង់គ្លេស បែលស៊ិក ស៊ុយអែត ក្រិច ហ្វាំងឡង់ អូស្រ្តៀ ស្វ៊ីសស៊ីឡែន និងណរវ៉េ។ រដ្ឋាភិបាលហូឡង់បានឆ្លើយទៅនឹងសំណួររបស់សមាជិកសភាម្នាក់នៅក្នុងសំណុំរឿង 'Tweede Kamer der Staten – Generaal', no. 587, 1976-1977, pp. 1171-1172 អត្ថបទជាភាសាហូឡង់ដូចខាងក្រោមនេះ៖

> *"Zoals bekend had de Regering, na de machtswisseling in Phnom Penh, in het belang van continuering van de relaties, reeds op 18 april 1975 besloten betrekkingen aan te knopen met de regering van Cambodja, zodra deze zou zijn gevormd. [...]*
> *Eerst op 3 november jl. gaf de regering te Phnom Penh van haar kant te kennen met ons land diplomatieke betrekkingen aan te willen knopen.[...]*
> *Van de andere lid-staten van de EG zijn inmiddels tot het aanknopen van betrekkingen overgegaan: Denemarken (mei 1976), Italië (juni 1976), VK (augustus 1976) en België (december 1976).*
> *Op bijgaande lijst staan de landen vermeld, die voor zover bekend, diplomatieke betrekkingen met Cambodja onderhouden.*
> *Relaties met Cambodja: [...]*
> *B. Sinds de machtswisseling tevens*
> *Zweden (april 1975) [...] Denemarken (mei 1976) [...] Italië (juni 1976) [...] Griekenland (augustus 1976) [...] Finland (augustus 1976), Oostenrijk (augustus 1976), Zwitserland (augustus 1976), Verenigd Koninkrijk (augustus 1976), Noorwegen (november 1976), België (december 1976)."*

មេធាវីការពារក្តីបកប្រែអត្ថបទនេះដោយខ្លួនឯងដូចតទៅ:

> "នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ ដើម្បីជាផលប្រយោជន៍ក្នុងការបន្តទំនាក់ទំនង រដ្ឋាភិបាលបានសម្រេចបង្កើតទំនាក់ទំនងជាមួយរដ្ឋាភិបាលកម្ពុជា នៅពេលណាដែលរដ្ឋាភិបាលត្រូវបានបង្កើត"[...]។ ទើបតែនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំមុននេះ រដ្ឋាភិបាលភ្នំពេញបានបញ្ជាក់អំពីបំណងរបស់ខ្លួនក្នុងការបង្កើតទំនាក់ទំនងទូតជាមួយប្រទេសហូឡង់[...]។
> ប្រទេសសមាជិកសហគមន៍អឺរ៉ុបមួយចំនួនទៀត ដែលមានទំនាក់ទំនងរួចជាស្រេចគឺ ដែណឺម៉ាក (ឧសភា ១៩៧៦) អ៊ីតាលី (មិថុនា ១៩៧៦) ចក្រភពអង់គ្លេស (សីហា ១៩៧៦) បែលស៊ិក (ធ្នូ ១៩៧៦)។
> បញ្ជីឈ្មោះប្រទេសដែលមានទំនាក់ទំនងជាមួយកម្ពុជារហូតមកដល់ពេលនេះមាន៖
> ទំនាក់ទំនងជាមួយកម្ពុជា [...]។
> ខ.ចាប់តាំងពីការផ្លាស់ប្តូរអំនាចមាន៖
> ស៊ុយអែត (មេសា ១៩៧៥) [...] ដែណឺម៉ាក (ឧសភា ១៩៧៦) អ៊ីតាលី (មិថុនា ១៩៧៦) ក្រិច (សីហា ១៩៧៦) ហ្វាំងឡង់ (សីហា ១៩៧៦) អូស្រ្តៀ (សីហា ១៩៧៦) ស្វ៊ីសស៊ីឡែន (សីហា ១៩៧៦) ចក្រភពអង់គ្លេស (សីហា ១៩៧៦) និងណរវ៉េ (វិច្ឆិកា ១៩៧៦) បែលស៊ិក (ធ្នូ ១៩៧៦)។

[14] សោ ភឹម និង រស់ ញឹម ត្រូវបានតែងតាំងតាមលំដាប់ជា អនុប្រធានទី១ និងទី២ នៃគណៈប្រធានរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យដោយសភាតំណាងប្រជាជន, សូមមើលឯកសារ **E3/165** "ឯកសារអង្គប្រជុំសន្និបាតលើកទី១ ក្នុងកាលសម័យទី១ របស់សភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី ១១ ១៣ ខែ មេសា ឆ្នាំ ១៩៧៦ , ERN 00184068។

កងទ័ពភូមិភាគ និងទំនាក់ទំនងផ្ទាល់ខ្លួនយ៉ាងជិតស្និទ្ធិរបស់គាត់ ជាមួយរស់ ញឹម ប្រហែលជាគាត់បានធ្វើសកម្មភាព តាមការណែនាំរបស់រស់ ញឹម ឬដោយមានការគាំទ្រ និងការយល់ព្រមពីគាត់។

## ឃ. ភ័ស្តុតាងបន្ថែមមកពី Rob Lemkin និងថេត សម្បត្តិ

10. នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន មេធាវីការពារក្តីបានស្នើដល់អង្គជំនុំជម្រះតុលាការកំពូល ឱ្យកោះហៅ Rob Lemkin និងថេត សម្បត្តិ មកផ្តល់សក្ខីកម្ម[15]។ សំណើនេះត្រូវបានធ្វើឡើងដោយផ្អែកជាពិសេសទៅលើសំណើចំនួនពីរកន្លងមក របស់មេធាវីការពារក្តី៖ សំណើរបស់មេធាវីការពារក្តី ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកភ័ស្តុតាងបន្ថែម (កិច្ចសម្ភាសវីដេអូ) ពី Rob Lemkin និងថេត សម្បត្តិ[16] និងសំណើរបស់មេធាវីការពារក្តី សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី SCW-5 ធ្វើជាភ័ស្តុតាង និងកោះហៅគាត់មក ផ្តល់សក្ខីកម្ម។ នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតដោយផ្អែកទៅលើសំណើសុំទទួលយកភ័ស្តុតាងរបស់ Rob Lemkin និង ថេត សម្បត្តិ និងចាប់ផ្តើមការស៊ើបអង្កេតបន្ថែមទៅលើបញ្ហានេះ[17]។ ខ្លួនបានបង្គាប់ WESU ឱ្យទាក់ទងទាំង Lemkin និង សម្បត្តិ ដើម្បីរៀបចំពេលវេលាសម្រាប់ស្តាប់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះ បើទោះជា WESU បានជូនដំណឹងថា សម្បត្តិដំបូងឡើយមិនបានឆ្លើយតបទៅនឹងការព្យាយាមច្រើនដងដើម្បីទាក់ទងគាត់[18]។ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានស្តាប់ចម្លើយ Rob Lemkin[19]។ Lemkin បានពន្យល់ទៅកាន់អង្គជំនុំជម្រះថា ក្នុងពេលខ្លួនផលិតខ្សែភាពយន្ត "*Enemies of the People* and *Suspicious Minds*",

---

[15] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៥៦៧, ៧៣០(ក)។

[16] ឯកសារ **F2**, 'សំណើសុំឱ្យទទួលយក និងពិចារណាភ័ស្តុតាងបន្ថែម ពាក់ព័ន្ធបណ្តឹងសាទុក្ខប្រឆាំងសាលក្រមក្នុងសំណុំរឿង ០០២/០១', ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤។

[17] ឯកសារ **F2/4/3**, 'សេចក្តីសម្រេចបណ្តោះអាសន្នលើសំណើសុំលើកទីមួយរបស់នួន ជា មួយផ្នែក ក្នុងការស្នើសុំឱ្យទទួលយក និងពិចារណាភ័ស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធី បណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១', ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥។

[18] **F2/4/3/2** "របាយការឆ្លើយតបទៅហ្នឹងសេចក្តីសម្រេចរបស់តុលាការកំពូល F2/4/3" ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៥ ("WESUរបាយការសម្បត្តិ") ទំព័រ ១។

[19] **F2/4/3/1** "កំណត់ហេតុស្តាប់ចម្លើយ Robert T.F. Lemkin" ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ ("កំណត់ហេតុស្តាប់ចម្លើយ Robert T.F. Lemkin")

គាត់និង សម្បត្តិមាន "ភស្តុតាងជាច្រើនអំពីរបៀបវិរៈនយោបាយរបស់ រស់ ញឹម នៅអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៨"។ ដោយរួមមានផងដែរនូវកិច្ចសម្ភាសន៍ជាមួយបុគ្គលបួនរូបដែល ចម្លើយរបស់គាត់គាំទ្របញ្ហានេះ៖

> របៀបវិរៈនយោបាយរបស់ រស់ ញឹម ទាក់ទងនឹងទស្សនៈរបស់គាត់ក្នុងការគ្រប់គ្រងបក្សកុម្មុយនិស្តកម្ពុជា ទស្សនៈរបស់គាត់អំពីមាគ៌ារបស់បក្សកុម្មុយនិស្តកម្ពុជា។ ទស្សនៈរបស់គាត់អំពីអ្វីដែលត្រូវធ្វើចំពោះមាគ៌ា។ ទស្សនៈ និងសកម្មភាពរបស់គាត់ក្នុងការព្យាយាមគ្រប់គ្រងបក្ស[20]។

11. Rob Lemkin ប្រាប់ថា គាត់មានបំណងផ្តល់ជូនវីដេអូនៃកិច្ចសម្ភាសន៍ទាំងនេះ ដរាបណាមាន ការយល់ព្រមពី ថេត សម្បត្តិ។ គាត់ក៏បានបញ្ជាក់ថា គាត់បានសរសេរអត្ថបទមួយមានចំនួន ១000 ពាក្យ ជាសេចក្តីដកស្រង់ ដែលគាត់មានបំណងផ្តល់ជូនអង្គជំនុំជម្រះ ដែល "សង្ខេបពី ព័ត៌មានដែលខ្លួនបានប្រមូលតាំងពីឆ្នាំ ២00៧ រហូតដល់ ឆ្នាំ ២០១១"[21]។ នៅបន្ទាប់ពីកិច្ច សម្ភាសន៍នេះ អង្គជំនុំជម្រះបានបង្គាប់ទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឲ្យព្យាយាមទាក់ ទងជាមួយ ថេត សម្បត្តិ ជាថ្មីម្តងទៀត។ នៅថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ ២០១៥ WESU បានរក សម្បត្តិ ឃើញដោយជោគជ័យ។ អង្គជំនុំជម្រះបានស្នើសុំនូវវីដេអូនៃកិច្ចសម្ភាសន៍ជាមួយបុគ្គល ទាំងបួនរូប។ ថេត សម្បត្តិ បានបដិសេធ ដោយលើកឡើងអំពីបំណងជាក់លាក់ដោយមានការ យល់ព្រមពីអ្នកទាំងបួនក្នុងការប្រើប្រាស់កិច្ចសម្ភាសន៍របស់គាត់ និងការផ្តល់ជូននូវកិច្ចសម្ភាស ន៍នឹងធ្វើឲ្យ សម្បត្តិ និងគ្រួសារសម្បត្តិ និងអតីតអ្នកបម្រើការងារស្ថិតនៅក្នុងភាពគ្រោះថ្នាក់[22]។

12. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចអន្តរ កាលមួយទៅលើការស៊ើបអង្កេតបន្ថែម[23]។ អង្គជំនុំជម្រះបានបង្គាប់ថា Rob Lemkin បានផ្តល់ កំណត់ហេតុរបស់គាត់នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ (កំណត់ហេតុ) ដោយភ្ជាប់ទៅនឹង

---

[20] **F2/4/3/1**, កំណត់ហេតុស្តាប់ចម្លើយ Robert T.F. Lemkin, ទំព័រ 10 (at A34).

[21] **F2/4/3/1**កំណត់ហេតុស្តាប់ចម្លើយ Robert T.F. Lemkin, ទំព័រ ១១ (at A36), 4 (at A6), and 11 (at A38).

[22] **F2/4/3/2**, អង្គភាពគាំពារសាក្សី និងអ្នកជំនាញ របាយការណ៍អំពីសម្បត្តិ ទំព័រ ១។

[23] **F2/4/3/3**, សេចក្តីសម្រេចអន្តរកាលរបស់អជតក, ទំព័រ 3; **F2/4/3/3.1**, 'សម្ងាត់: កំណត់ត្រាមិនទាន់បោះពុម្ពអំពីជម្លោះផ្ទៃក្នុងរបស់ខ្មែរក្រហម',ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ២០១៥។.

សេចក្ដីសម្រេចរបស់ខ្លួន[24]។ ដោយពិចារណាទៅដល់ការបដិសេធរបស់ ថេត សម្បត្តិ ក្នុងការវីដេអូ ឬក៏ប្រតិចារិត អង្គជំនុំជម្រះបានស្នើសុំមេធាវីការពារក្ដីដាក់នូវសារណាជាលាយលក្ខអក្សរថា តើកំណត់ហេតុរបស់ Lemkin គួរត្រូវបានទទួលយកជាភស្តុតាង និង "វិធានការបន្ថែមទៀត ដោយចៅក្រមដែលទទួលសិទ្ធិ ឬ អង្គជំនុំជម្រះទាក់ទងនឹងពត៌មានដែលកើតចេញពីការស៊ើបអង្កេតបន្ថែម"[25]។

## II. ភ័ស្តុតាងបន្ថែម

13. មេធាវីការពារក្ដីស្នើដល់អង្គជំនុំជម្រះឲ្យទទួលយក ភ័ស្តុតាងបន្ថែមចំនួនប្រាំមួយ និងកោះហៅសាក្សីបណ្ដឹងសាទុក្ខបន្ថែមប្រាំនាក់ទៀត។ ភស្តុតាងបន្ថែមនេះនឹងរៀបរាប់លម្អិតនៅកថាខណ្ឌ ១៤ ដល់ ១៨ និងសង្ខេបដូចខាងក្រោមនេះ៖

(ក) មេធាវីការពារក្ដីស្នើសុំឲ្យទទួលយក កំណត់ហេតុស្ដាប់ចម្លើយដែលត្រូវបានដាក់បង្ហាញមកមេធាវីការពារក្ដីកាលពីពេលថ្មីៗនេះ ដែលរួមមានភ័ស្តុតាងរបស់សាក្សីចំនួនបួននាក់ [redacted]។ មេធាវីការពារក្ដីក៏បានស្នើដល់អង្គជំនុំជម្រះតុលាការកំពូល ឲ្យកោះហៅសាក្សីពីរនាក់ក្នុងចំណោមសាក្សីទាំងនោះ មកផ្ដល់សក្ខីកម្ម។

(ខ) មេធាវីការពារក្ដីក៏បានស្នើដល់អង្គជំនុំជម្រះ ឲ្យកោះហៅសាក្សីបន្ថែមបីនាក់ទៀតឲ្យមកផ្ដល់សក្ខីកម្ម។ មេធាវីការពារក្ដីបានស្នើសុំរួចម្ដងមកហើយដើម្បីផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ដែលភ័ស្តុតាងរបស់គាត់មាននៅក្នុងសំណុំរឿង ០០២ គឺនៅក្នុងសៀវភៅ *Behind the Killing Fields* ។ ប៉ុន្តែពួកគាត់មិនដែលមកផ្ដល់សក្ខីកម្មនៅក្នុង

[24] **F2/4/3/3**, សេចក្ដីសម្រេចអន្តរកាលរបស់អជតក, ទំព័រ 3; **F2/4/3/3.1**, 'សម្ងាត់: កំណត់ត្រាមិនទាន់បោះពុម្ពអំពីជម្លោះផ្ទៃក្នុងរបស់ខ្មែរក្រហម',ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ២០១៥។

[25] **F2/4/3/3**, សេចក្ដីសម្រេចអន្តរកាលរបស់អជតក, ទំព័រ៣។ មេធាវីការពារក្ដីកត់សម្គាល់ថា សំណើនេះអាចផ្ដល់ព័ត៌មានទាក់ទង ក្នុងការឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះឲ្យដាក់សារណាទាក់ទងនឹងកំណត់ត្រារបស់ Lemkin ។ ទោះជាយ៉ាងណាក៏ដោយមេធាវីការពារក្ដីមិនទាន់បានពិចារណានៅលើទេអំពីកំណត់ត្រានោះ និងអាស្រ័យហេតុនេះហើយមិនទាន់ឆ្លើយតបទៅនឹងព័តមានណាមួយនៅក្នុងកំណត់ត្រានោះនៅឡើយទេនៅក្នុងសំណើនេះ។ ហើយខ្លួននឹងដាក់សេចក្ដីសន្និដ្ឋានលើបញ្ហានេះនៅសារណាដោយឡែកក្នុងពេលឆាប់ៗ។

តុលាការ នាពេលកន្លងមក ឬត្រូវបានស្តាប់ចម្លើយដោយ ក.ស.ចៈស ឡើយ។

(គ) មេធាវីការពារក្តី ស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយទីពីរ របស់សាក្សីបណ្តឹងសាទុក្ខដែលនឹងមកបង្ហាញខ្លួន គឺសាក្សី SCW-5 ព្រមទាំងឧបសម្ព័ន្ធនៃកំណត់ហេតុស្តាប់ចម្លើយរបស់គាត់។

## ក. កំណត់ហេតុស្តាប់ចម្លើយសាក្សីបួននាក់ [redacted]

### *(i) កំណត់ហេតុស្តាប់ចម្លើយសាក្សីទីមួយ (និរសា និងកងការពាររបស់ ញឹម)*[26]

14. ភស្តុតាងទីមួយដែលមេធាវីការពារក្តី ស្នើសុំឱ្យទទួលយកគឺកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទីមួយ។ សាក្សីទីមួយត្រូវបានស្តាប់ចម្លើយ ដោយ [redacted] នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣[27] [redacted]។ សាក្សីទីមួយក៏ជាសាក្សីដំបូងនៅក្នុងសំណើនេះ ដែលមេធាវីការពារក្តីបានស្នើសុំឱ្យកោះហៅ ក្នុងនាមជាសាក្សីបណ្តឹងសាទុក្ខ។ [redacted]។

15. សាក្សីទីមួយបានចូលរួមក្នុង "បដិវត្តខ្មែរក្រហម" ក្នុងឆ្នាំ ១៩៧២។ ដំបូងគាត់ត្រូវបានគេចាត់តាំងឱ្យធ្វើការក្នុង "ផ្នែកសិល្បៈ" ហើយបន្ទាប់មកត្រូវបានតែងតាំងជានិរសារបស់របស់ ញឹម

---

[26] មេធាវីការពារក្តីបានយោងទៅលើសាក្សី ដោយប្រើត្រឹមរហស្សនាមប៉ុណ្ណោះ យោងតាមការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថាខ្លួន "កំណត់អត្តសញ្ញាណសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤ តែត្រឹមរហស្សនាមដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ឬកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២ ឬក៏ប្រើប្រាស់តែត្រឹមពាក្យទូទៅដែលត្រូវបានគិតគូរយ៉ាងសមហេតុផល ដើម្បីជៀសវាងការកំណត់អត្តសញ្ញាណសាក្សី"៖ សូមមើល ឯកសារ **F22**, 'ការណែនាំពាក់ព័ន្ធសាក្សីដែលបានស្នើឡើង ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ នៃសំណុំរឿង ០០២/០១', ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥, កថាខណ្ឌ ៦(ឃ)។ សាក្សីភាគច្រើនដែលទាក់ទងនឹងសំណើនេះ មិនដែលត្រូវបានកំណត់រហស្សនាមនៅឡើយ ដោយអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល។ ហេតុដូចនេះទើបមេធាវីការពារក្តី បានកំណត់រហស្សនាមដោយខ្លួនឯង សម្រាប់សាក្សីទាំងអស់នេះ។

[27] ឯកសារ **E319/19.3.107**, 'កំណត់ហេតុស្តាប់ចម្លើយ [សាក្សីទីមួយ]', ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ("កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១")។

[28] [redacted]

ហើយបានចូលក្នុងកងទ័ពប្រជាជនរំដោះជាតិកម្ពុជាក្នុងឆ្នាំ ១៩៧៤។ ចាប់តាំងពីឆ្នាំ ១៩៧៦មក គាត់ត្រូវបានគេតែងតាំងជាកងការពាររបស់រស់ ញឹម[29]។

16. នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ សាក្សីទីមួយបានរៀបរាប់ពីឆ្នាំ ១៩៧៧ ដែលគាត់បានអមដំណើរ រស់ ញឹម ក្នុងនាមជាកងការពាររបស់គាត់ ធ្វើដំណើរទៅតំបន់មួយនៅជាប់ព្រំដែនវៀតណាម ដែលនៅតំបន់នោះពួកគេបានប្រមូលឯកសណ្ឋានកងទ័ពពីវៀតណាម ហើយយកឯកសណ្ឋានទាំងនោះមកមន្ទីររបស់រស់ ញឹម នៅអំពិលប្រហោង៖

> ឆ៣៖ ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ ខ្ញុំមកនៅកងហាត រហូតដល់ឆ្នាំ ១៩៧៦ ទើបតា ញឹម គាត់ហៅខ្ញុំឲ្យមកធ្វើជាកងការពាររបស់គាត់ ហើយខ្ញុំនៅធ្វើជាកងការពាររបស់គាត់ រហូតដល់ពេលគេចាប់ខ្លួនគាត់តែម្ដង។ កាលណោះខ្ញុំតាមការពារគាត់គ្រប់ទីកន្លែង ហើយគាត់មានអ្នកការពារបីនាក់រួមទាំងខ្ញុំ តែខ្ញុំមិនមែនជាអ្នកដែលជិះឡានជាមួយគាត់ទេ។ <u>ខ្ញុំធ្លាប់ជូនតា ញឹម ទៅភ្នំដិន នៅជាប់ព្រំដែនវៀតណាម។</u>
>
> ស៖ តើហេតុអ្វីបានជាលោកទៅភ្នំដិន ជាមួយតា ញឹម?
>
> ឆ៤៖ <u>គាត់ឲ្យខ្ញុំការពារពេលដឹកខោអាវយោធាពីភ្នំដិន មកដាក់នៅអំពិលប្រហោង និងនៅស៊ីសុផុន ក្នុងឆ្នាំ ១៩៧៧។</u> ស៊ីសុផុនក៏ជាកន្លែងយោធារបស់តា ញឹមដែរ។
>
> ស៖ តើអំពិលប្រហោងជាកន្លែងអ្វីដែរ?
>
> ឆ៥៖ <u>អំពិលប្រយោងជាផ្ទះតា ញឹម និងក៏ជាកន្លែងគាត់ធ្វើការដែរ។</u> អំពិលប្រហោងមានទីតាំងនៅខាងលិចផ្សារលើ ចម្ងាយ១ គ.ម។
>
> ស៖ តើគេយកខោអាវទាហាននោះមកធ្វើអ្វីដែរ?
>
> ឆ៦៖ ខ្ញុំមិនដឹងថាគេយកមកឲ្យនរណាទេ តែ<u>តា ញឹម ប្រាប់ខ្ញុំថា ខោអាវនោះគឺយកពីយួន</u>[30]។

17. សាក្សីទីមួយក៏បានពន្យល់ផងដែរពីកាលៈទេសៈ ដែលរស់ ញឹម ត្រូវបានចាប់ខ្លួនដោយកម្មាភិបា

---

[29] ឯកសារ **E319/19.3.107**, កំណត់ហេតុស្ដាប់ចម្លើយសាក្សីទី ១, ទំព័រ ៣។

[30] ឯកសារ **E319/19.3.107**, កំណត់ហេតុស្ដាប់ចម្លើយសាក្សីទី ១, ទំព័រ ៣ដល់៤ (មានការគូសបញ្ជាក់, ឃ្លាជាភាសាខ្មែរត្រូវបានលុបចេញ)។

លក្ខមិភាគនិរតី នៅ "ប្រហែលចុងឆ្នាំ ១៩៧៨" ហើយបន្ទាប់មកត្រូវបានគេសម្លាប់[31]៖

ឆ១២៖ ខ្ញុំធ្វើការជាមួយគាត់នៅអំពិលប្រហោង។ កន្លែងនោះជាផ្ទះរបស់គាត់ផង និងជាកន្លែងគាត់ធ្វើការផង។

ស៖ តើមានរឿងអ្វីកើតឡើងចំពោះតា ញឹម?

ឆ១៣៖ ពួកនិរតីចាប់គាត់ កាលណោះគេចាប់គាត់នៅស៊ីសុផុន នៅពេលគាត់រត់សំដៅទៅកំពង់ចាម។

ស៖ តើលោកអាចបញ្ជាក់ឱ្យច្បាស់បានទេថា ពួកនិរតីដែលចាប់តា ញឹម នោះឈ្មោះអ្វី?

ឆ១៥៖ ពួកនិរតីនោះឈ្មោះតា ណុប និងតា ម៉ុក ខ្ញុំស្គាល់តែពីរនាក់នោះទេ។

ស៖ តើតា ណុប និងតា ម៉ុក មានមុខងារអ្វីដែរ?

ឆ១៦៖ គាត់ទាំងពីរនោះជាមេធំមកពីភ្នំពេញ ដែលមកចាប់តា ញឹម នៅបាត់ដំបង តែតា ញឹម ដឹងពីរឿងនេះ គាត់ក៏គេចខ្លួនទៅស៊ីសុផុន ហើយគេចាប់គាត់បាននៅកន្លែងនោះ

ស៖ តើហេតុអ្វីបានជាតា ញឹម គាត់រត់គេចខ្លួន?

ឆ១៩៖ ដោយសារតែពេលនោះមានយោធាពីនិរតី២ឡាន គេចុះមកឆែកផ្ទះគាត់ ហើយពួកអ្នកការពារគាត់កុហកយោធាទាំងនោះថា តា ញឹម ទៅក្រុងបាត់ដំបងបាត់ហើយ រួចអ្នកការពារផ្តល់ដំណឹងនេះដល់គាត់ ហើយគាត់គេចខ្លួនតែម្តង។

ស៖ តើលោកធ្វើដូចម្តេចទើបលោកដឹងថា យោធាទាំងនោះមកពីនិរតី?

ឆ២០៖ ខ្ញុំដឹងដោយសារតែពួកនោះ ជាអ្នកដើរចាប់មេធំៗរបស់ពាយ័ព្យ។ តា ណុប គាត់ជាអ្នកបញ្ជាឱ្យចាប់មេៗនោះ។ មេធំៗរបស់ពាយ័ព្យដែលគេចាប់ខ្លួនមានដូចជាតា វ៉ាញ ជាគណៈតំបន់១, តា វែងជាអ្នកការពារតា វ៉ាញ។

ស៖ តើមានរឿងអ្វីកើតឡើងចំពោះតា ញឹម ក្រោយពេលគេចាប់ខ្លួនគាត់?

[31] ឯកសារ **E319/19.3.107**, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១, ទំព័រ ៥។

ឆ២៣៖ គេយកគាត់ទៅសម្លាប់ចោល ព្រោះខ្ញុំឮពួកនិរតីគេនិយាយគ្នា នៅទល់ដែនថៃ ក្រោយឆ្នាំ ១៩៧៩[32]។

18. បន្ទាប់ពីចាប់ខ្លួន រស់ ញឹម សាក្សីទីមួយត្រូវបានគេចាប់ខ្លួន។ ដំបូងគាត់ត្រូវបានគេឃុំខ្លួននៅមន្ទីរសន្តិសុខ ក្នុងខេត្តបាត់ដំបង[33]។ គាត់និយាយថា នៅទីនោះគាត់ត្រូវបានសួរចម្លើយដោយកងទ័ពពីរនាក់ "មកពីភូមិភាគកណ្តាល និងនិរតី"[34] ដែលសំណួររបស់ពួកគេនោះ ផ្តោតសំខាន់លើការធ្វើដំណើរជាមួយរស់ ញឹម ទៅវៀតណាម៖

ឆ៤១៖ គេមានអ្នកសួរចម្លើយពីរនាក់ តែខ្ញុំមិនដែលស្គាល់គេទេ គេសួរខ្ញុំដដែលៗថា "អ្អែងទៅយួនប៉ុន្មានដង" ហើយខ្ញុំឆ្លើយថាខ្ញុំមិនដែលបានទៅទេ រួចគេថា "អ្អែងជានិរសាររបស់តា ញឹម អញមិនជឿអ្អែងទេ អ្អែងប្រាកដជាធ្លាប់ទៅយួន" រួចគេក៏យកប្រដាប់ឆក់ប៉ុនទូរសព្ទមកឆក់ត្រង់កខ្ញុំ រហូតដល់ខ្ញុំសន្លប់[35]។

19. សាក្សីទីមួយនៅពេលក្រោយមកត្រូវបានបញ្ជូនទៅគុក កកោះ ដែលគាត់បានរៀបរាប់ដូចតទៅ៖

ឆ២៥៖ អ្នកទោសនៅទីនោះជាអតីតយោធាពាយ័ព្យ ដែលពួកនិរតីចាប់បាន។

ស៖ តើមានអ្នកទោសប៉ុន្មាននាក់នៅកកោះនោះ?

ឆ២៦៖ ច្រើននាក់ដែរ ព្រោះរោងដាក់អ្នកទោសនោះវែង[36]។

20. សាក្សីទីមួយក៏បានរៀបរាប់ពីការមកដល់ "ចាប់ពីឆ្នាំ ១៩៧៧"[37] របស់កម្មាភិបាលភូមិភាគនិរតីមកភូមិភាគពាយ័ព្យ ព្រមទាំងសកម្មភាពរបស់ពួកគេនៅពេលមកដល់៖

ឆ៩៖ ពេលគេចូលមកគេដកមេភូមិ និងឃុំចេញ ហើយគេឡើងធ្វើមេភូមិ មេឃុំដោយខ្លួន

---

[32] ឯកសារ **E319/19.3.107**, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១, ទំព័រ ៥ ដល់៦ (មានការគូសបញ្ជាក់, ឃ្លាជាភាសាខ្មែរត្រូវបានលប់ចេញ)។

[33] ឯកសារ **E319/19.3.107**, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១, ទំព័រ ៨។

[34] ឯកសារ **E319/19.3.107**, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១, ទំព័រ ៩ (នៅត្រង់ ឆ៤៣)។

[35] ឯកសារ **E319/19.3.107**, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១, ទំព័រ ៩ (មានការគូសបញ្ជាក់)។

[36] ឯកសារ **E319/19.3.107**, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១, ទំព័រ ៧ (មានការគូសបញ្ជាក់, ឃ្លាជាភាសាខ្មែរត្រូវបានលប់ចេញ)។

[37] ឯកសារ **E319/19.3.107**, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១, ទំព័រ ៤ (នៅត្រង់ ឆ៨)។

គេតែម្តង។ ពេលពួកនិរតីចូលមកគេមើលដែរ បើនរណាខ្លាំងដាក់គេ គេដកចេញ បើអ្នកណាចំណុះគេ នោះគេទុកនៅដដែល។ គេដកចេញពីមានន័យថាគេយកទៅសម្លាប់ចោល។ ចំពោះតំបន់ និងភូមិភាគ ក៏គេដកចេញដែរ[38]។

21. បន្ថែមលើនេះ គាត់បានផ្តល់ព័ត៌មានលម្អិតអំពីគ្រួសាររបស់ ញឹម៖

ឆ៥៥៖ តា ញឹម គាត់មានកូនបួននាក់ កូនស្រីម្នាក់ និងប្រុសបីនាក់ ហើយស្រីជាកូនពៅ ទី១) ឈ្មោះ ជៀល, ទី២) ឆ្នាំង, ទី៣) ឈ្មោះ ស៊ីហួរ និងពៅគេឈ្មោះកញ្ញ្រែង។

22. ជាចុងក្រោយសាក្សីទីមួយបានផ្តល់ព័ត៌មានទាក់ទង ប្រតិបត្តិការរបស់ភូមិភាគពាយ័ព្យ៖

ឆ៦២៖ មន្ទីរភូមិភាគពាយ័ព្យមានពីរកន្លែង គឺនៅអំពិលប្រយោងមួយកន្លែង និងមួយកន្លែងទៀតនៅស្វាយស៊ីសុផុន។ នៅស៊ីសុផុន គឺជាកន្លែងរបស់ឆ្នាំង តែខ្ញុំមិនដឹងថាគាត់មានតួនាទីអ្វីទេ។ នៅអំពិលប្រហោង គឺតា ញឹម ប្រើសម្រាប់ប្រជុំជាមួយមេៗយោធា តែខ្ញុំមិនស្គាល់មេៗយោធាទាំងនោះទេ ព្រោះគេមិនឲ្យខ្ញុំចូលទៅកន្លែងប្រជុំនោះទេ។

ស៖ តើតា ញឹម គាត់ទាក់ទងមកខាងតំបន់ដោយរបៀបណា?

ឆ៦៥៖ គាត់ប្រើទូរសព្ទ និងនិរសា ដើម្បីទំនាក់ទំនងគ្នា។

ស៖ តើលោកស្គាល់ឈ្មោះនិរសាររបស់តា ញឹម នោះដែរឬទេ?

ឆ៦៦៖ និរសាររបស់គាត់មានបីនាក់ ខ្ញុំចាំឈ្មោះតែម្នាក់ទេគឺឈ្មោះ ជ្រូក ហើយខ្ញុំមិនដឹងថាជ្រូក ស្លាប់ឬក៏រស់នោះទេ[39]។

### *(ii) កំណត់ហេតុស្តាប់ចម្លើយ សាក្សីទីពីរ (អតីតប្រធានភស្តុភារ និងសេដ្ឋកិច្ច ភូមិភាគពាយ័ព្យ)*

23. ភស្តុតាងទីពីរដែលមេធាវីការពារក្តី ស្នើសុំឲ្យទទួលយកគឺកំណត់ហេតុស្តាប់ចម្លើយ របស់សាក្សីទីពីរ។ សាក្សីទីពីរត្រូវបានស្តាប់ចម្លើយដោយ [redacted] កាលពីថ្ងៃទី

[38] ឯកសារ E319/19.3.107, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១, ទំព័រ ៤ ដល់៥ (មានការគូសបញ្ជាក់, មានការកែតម្រូវចំពោះឯកសារច្បាប់ដើម)។

[39] ឯកសារ E319/19.3.107, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ១, ទំព័រ ៤ដល់៥ (មានការគូសបញ្ជាក់, មានការកែតម្រូវចំពោះឯកសារច្បាប់ដើម, ឃ្លាជាភាសាខ្មែរត្រូវបានលប់ចេញ)។

២២ ខែ កញ្ញា ឆ្នាំ ២០១៣[40] [redacted]។ សាក្សីនេះគឺជាសាក្សីទីពីរនៅក្នុងសំណើនេះ ដែលមេធាវីការពារក្តីបានស្នើសុំឲ្យកោះហៅ ក្នុងនាមជាសាក្សីបណ្តឹងសាទុក្ខ។ [redacted]។

24. ចាប់ពីឆ្នាំ ១៩៧៣ រហូតដល់ខែ មេសា ឬឧសភា ឆ្នាំ ១៩៧៦ សាក្សីទីពីរគឺជាប្រធានភស្តុភារ និងសេដ្ឋកិច្ចរបស់ភូមិភាគពាយ័ព្យ។ ក្រោយមកគាត់ត្រូវបានផ្លាស់ទៅកងនេសាទ នៅតំបន់៤ ក្នុងភូមិភាគពាយ័ព្យជិតបឹងទន្លេសាប។ នៅក្នុងខែ មីនា ឬមេសា ឆ្នាំ ១៩៧៨ កងកម្លាំងភូមិភាគនិរតី បានចាប់ខ្លួនប្រធានកងរបស់គាត់ និងមិត្តរួមការងាររបស់គាត់ ហើយបានរំលាយកងនេះ។ ប៉ុន្តែ សាក្សីទីពីរអាចគេចផុតពីការចាប់ខ្លួនបាន រហូតដល់ពេលវៀតណាមឈ្លានពានដល់[42]។

25. នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ សាក្សីទីពីរបានពន្យល់ថា *"តាញឹមត្រូវចាប់ខ្លួនជំណាលគ្នា និងលេខាភូមិភាគបូព៌ាឈ្មោះ សោ ភឹម"*[43]។ គាត់ក៏បានរៀបរាប់អំពីអ្វី ដែលហាក់ដូចជាការចាប់ខ្លួនជាទ្រង់ទ្រាយធំ នៅទូទាំងភូមិភាគពាយ័ព្យ នៅគ្រប់កម្រិតទាំងអស់៖

> ឆ២៖ នៅដើមឆ្នាំ ១៩៧៨ គេចាប់ផ្តើមបំបែកពួកខ្ញុំ ដោយសារតែមានបញ្ហានយោបាយ ព្រោះខាងនិរតីដែលដឹកនាំដោយតាម៉ុក ចាប់ផ្តើមចាប់កម្មាភិបាលថ្នាក់ភូមិភាគ តំបន់ ស្រុក និងនៅខាងទ័ព។ ប្រហែលជាខែ ៣ ឬខែ ៤ ឆ្នាំ ១៩៧៨ គេចាប់ប្រធានអង្គភាពរបស់ខ្ញុំឈ្មោះតា ស៊ុម ហើយកាលណោះខ្ញុំជាអនុប្រធានរបស់គាត់។ បន្ទាប់ពីចាប់ខ្លួនប្រធានខ្ញុំហើយ ខ្ញុំនៅធ្វើការនៅអង្គភាពនេសាទមិនដល់មួយខែ ទើបពួកនិរតីជិះកាណូតទៅគៀរកម្លាំងអង្គភាពនេសាទយោធា ហើយគេរំលាយអង្គភាពខ្ញុំ រួចគេយកគ្នាខ្ញុំមួយចំនួនទៅដាក់នៅកោះ ដែលជាកន្លែងកែប្រែរបស់យោធា និងខ្លះគេយកទៅដាក់នៅខាងភ្នំ

[40] ឯកសារ **E319/13.3.17**, 'កំណត់ហេតុស្តាប់ចម្លើយ[សាក្សីទី ២]', ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៣ ("កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ២")។

[41] [redacted]

[42] ឯកសារ **E319/13.3.17**, Witness 2 កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ២, ទំព័រ ៣ដល់៤ (នៅត្រង់ ឆ២)។

[43] ឯកសារ **E319/13.3.17**, Witness 2 កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ២, ទំព័រ ៤ (នៅត្រង់ ឆ៦, មានការគូសបញ្ជាក់, ឃ្លាជាភាសាខ្មែរត្រូវបានលុបចេញ)។

ធិបតី ខ្លះបញ្ជូនឲ្យនៅតាមសហករណ៍។

សៈ ក្រៅពីស៊ុម ដែលជាប្រធានអង្គភាពនេសាទ តើមាននរណាផ្សេងទៀតដែរឬទេ?

ឆ៥៖ កាលណោះមានតា ឆាំ មានតា ខ្លែង និងតា ហាំ។ អ្នកដែលគេចាប់ចុងក្រោយគេ គឺតា ញឹម។ តាមខ្ញុំដឹងតា ខ្លែង ដែលជាសេនាធិការយោធាភូមិភាគ ប្រហែលជាគេយកទៅដាក់នៅស-២១។ មុនដំបូងបង្អស់គេចាប់ប្រធានកងពលលេខ ១ និងលេខ ២ រួចទើបគេបន្តចាប់មេវរៈសេនាធំ មេវរៈសេនាតូច និងកងកាំភ្លើងធំ។

ឆ៦៖ [...] ក្នុងគណៈភូមិភាគ [...] តា កឹត្រូវបានគេចាប់មុនគេ [...][44]។

26. ប៉ុន្តែយោងតាមសាក្សីទីពីរ កម្មាភិបាលខ្លះអាចរត់ចូលព្រៃបាន ហើយបន្ទាប់មកបានបង្កើតជា "ចលនាខ្មែរស"៖

ឆ១២៖ [...] ខ្ញុំដឹងថានៅពេលវឹកវរ ពួកកម្មាភិបាលពាយ័ព្យមួយចំនួនរត់ចូលព្រៃ ហើយខ្លះត្រូវគេចាប់ខ្លួន។

សៈ តើកម្មាភិបាលពាយ័ព្យដែលរត់ទៅព្រៃ មាននៅរស់សព្វថ្ងៃនេះដែរឬទេ?

ឆ១៣៖ ពួកដែលរត់ទៅព្រៃគេបង្កើតចលនាខ្មែរស ហើយបានសម្លាប់ពួកនិរតីទៀតផង។ មកដល់សព្វថ្ងៃនេះ ខ្ញុំមិនដឹងថានរណានៅរស់ទេ ព្រោះអ្នកខ្លះមកខាងស្រុកមោង និងខាងពោធិ៍សាត់[45]។

27. សាក្សីទីពីរបានរៀបរាប់ពីការដែលកងទ័ពភូមិភាគនិរតី បានប្រើប្រាស់ "លេស" ជាច្រើនដើម្បីពន្យល់ពីការចូលមកភូមិភាគពាយ័ព្យដំបូងរបស់ពួកគេ ហើយក្នុងពេលជាមួយគ្នានេះ "បានតាមដានដោយសម្ងាត់" ចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ មុនពេលចាប់ផ្តើមធ្វើការចាប់ខ្លួន៖

ឆ១២៖ [...] ពេលពួកនិរតីចូលមកភូមិភាគពាយ័ព្យដំបូង គេមកធ្វើការជាមួយពួកពាយ័ព្យ

[44] ឯកសារ E319/13.3.17, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ២, ទំព័រ ៣ ដល់៤ (មានការគូសបញ្ជាក់, ឃ្លាជាភាសាខ្មែរត្រូវបានលប់ចេញ)។

[45] ឯកសារ E319/13.3.17, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ២, ទំព័រ ៦ (មានការគូសបញ្ជាក់, ឃ្លាជាភាសាខ្មែរត្រូវបានលប់ចេញ)។

ដោយមិនទាន់ធ្វើការចាប់ខ្លួនអ្វីទេ គឺគេមកតាមដានពួកពាយ័ព្យ។ [...]

ឆ៣៦៖ [...] មុនដំបូងពួកនិរតីចូលមកធ្វើការងារធម្មតាជាមួយពួកពាយ័ព្យ គេថាគេមកជួយពួកពាយ័ព្យ តែតាមពិតគេមកដើម្បីស៊ើបអង្កេតពួកពាយ័ព្យ។ [...]

ឆ៣៩៖ ពេលពួកនិរតីមកដំបូងគឺចុងឆ្នាំ ១៩៧៦ ហើយគេប្រើល្បិច គឺថ្នាក់ដឹកនាំគេថា គេផ្ញើម្នាក់នេះដើម្បីឱ្យអប់រំផង ព្រោះគេនោះបានធ្វើខុសនៅភូមិភាគនិរតី តែតាមពិតពួកនេះហើយគឺជាអ្នកមកស៊ើបការណ៍។ ហើយបានប្រហែល៣ ទៅ៤ខែ គឺក្នុងពាក់កណ្ដាលឆ្នាំ ១៩៧៧ ទើបគេបញ្ជូនកម្មាភិបាលនិរតីមកបន្ថែមទៀត មកធ្វើការបោសសម្អាត និងកាន់ក្ដាប់ភូមិភាគពាយ័ព្យ។ ដូចជាករណីការចាប់តា ញឹម គឺខាងភ្នំពេញគេបញ្ជូនមនុស្សមកធ្វើជានិរសារបស់គាត់ មុនគេចាប់គាត់[46]។

28. ដោយរៀបរាប់ពីមូលហេតុនៃការចាប់ខ្លួន សាក្សីទីពីរបាននិយាយថាកម្មាភិបាលភូមិភាគនិរតីបានចាប់ផ្ដើមបំបែកដៃគូភូមិភាគពាយ័ព្យ "ដោយសារបញ្ហានយោបាយ"[47] ហើយការចាប់ខ្លួនបានកើតឡើងនៅពេលចុងក្រោយ ដើម្បីរារាំងមិនឱ្យដឹងអំពីផែនការវាយបក ប្រឆាំងប៉ុល ពត ដែលដូច្នេះហើយអាចរារាំងភូមិភាគពាយ័ព្យ មិនឱ្យបះបោរដូចភូមិភាគបូព៌ា។ សាក្សីទីពីរក៏បានពន្យល់ពីតួនាទីរបស់បុគ្គលម្នាក់ឈ្មោះ តា ហំ ក្នុងការពាក់ព័ន្ធជាមួយផែនការនេះ៖

ស៖ តើលោកដឹងថាមានរឿងអ្វីកើតឡើងចំពោះតា ហំ?

ឆ២៩៖ តា ហំក៏គេចាប់ដែរ គឺចាប់ក្នុងពេលជាមួយគ្នានោះ។ តាមខ្ញុំក្ដាប់ព័ត៌មានគឺថា កងពលទាំងពីររបស់ភូមិភាគពាយ័ព្យ គឺមានផែនការណ៍ចង់វាយបកទៅខាងប៉ុល ពត តែត្រូវបែកការណ៍ដោយសារតែមានភ្នាក់ងារពីមជ្ឈិម គេដឹងពីរឿងនេះ ដូចនេះហើយបានជាគេចាប់ខាងយោធា។ តា ហំ គេចាប់ដោយសារគេចោទថា គាត់បានដឹកសម្ភារៈយោធាទៅទុកនៅភ្នំវាយចាប ហើយខ្ញុំដឹងរឿងនេះនៅក្រោយឆ្នាំ ១៩៧៩ ពីអ្នកដែលបើកឡានដឹកសម្ភារៈយោធានោះតែម្ដង។ មានយោធាផ្សេងទៀតប្រាប់ខ្ញុំថា គាត់បានស្ដាប់ឮពីមេៗគេប្រជុំគ្នានិយាយថា ប្រសិនបើមិនធ្វើអ្វីពួកភូមិភាគពាយ័ព្យ ភូមិភាគនេះនឹងបះបោរដូចគ្នា

[46] ឯកសារ **E319/13.3.17**, Witness 2 កំណត់ហេតុស្ដាប់ចម្លើយសាក្សីទី , ទំព័រ ៥, ៩, ១០ (មានការគូសបញ្ជាក់)។

[47] ឯកសារ **E319/13.3.17**, កំណត់ហេតុស្ដាប់ចម្លើយសាក្សីទី ២, ទំព័រ ៣។

នឹងភូមិភាគបូព៌ាដែរ[48]។

29. [redacted]។

30. ជាចុងក្រោយសាក្សីទីពីរ បានផ្តល់ព័ត៌មានលម្អិតអំពីមេដឹកនាំភូមិភាគពាយ័ព្យ និងរចនាសម្ព័ន្ធភូមិភាគ មុនពេលដែលកម្មាភិបាលភូមិភាគនិរតីចូលមកគ្រប់គ្រង ហើយព័ត៌មានទាំងអស់នោះរួមមាន៖

> សៈ លោកនិយាយពីតា ញឹម តើគាត់មានតួនាទីអ្វីនៅភូមិភាគពាយ័ព្យនេះ?
>
> ឆ៦៖ តា ញឹម គាត់ជាលេខាភូមិភាគ។ នៅក្នុងគណៈភូមិភាគមាន តា រស់ ញឹម, តា កឹ ហៅតា កន និងតា សាន។ [...]
>
> សៈ លោកនិយាយថានៅភូមិភាគពាយ័ព្យមានពីរកងពល តើនរណាជាប្រធានកងពលទាំងពីរនោះ?
>
> ឆ៤៦៖ ខ្ញុំភ្លេចឈ្មោះប្រធានកងពលលេខ ១ តែប្រធានកងពលលេខ ២ ឈ្មោះតា រ៉េន។ [...]
>
> សៈ តើលោកដឹងថា តា រ៉េន ត្រូវរាយការណ៍ទៅនរណាដែរ?
>
> ឆ៤៧៖ តា រ៉េន ត្រូវរាយការណ៍ទៅតា ខ្លែង ដែលជានាយសេនាធិការយោធាភូមិភាគពាយ័ព្យ។
>
> សៈ តើលោកដឹងថាតា ខ្លែង រាយការណ៍បន្តទៅនរណាគេដែរ?

---

[48] ឯកសារ **E319/13.3.17**, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ២, ទំព័រ ៨ (មានការគូសបញ្ជាក់, ឃ្លាជាភាសាខ្មែរត្រូវបានលប់ចេញមានការគូសបញ្ជាក់, ឃ្លាជាភាសាខ្មែរត្រូវបានលប់ចេញ)។

[49] សូមមើល, ឯកសារ **E319.1.27**, 'កំណត់ហេតុស្តាប់ចម្លើយ [សាក្សី SCW-5]', ចុះថ្ងៃទី ១០, (និង១១ និង១២) ខែ កញ្ញា ឆ្នាំ ២០១៣ ("កំណត់ហេតុស្តាប់ចម្លើយសាក្សី SCW-5 ទី១"), ទំព័រ ៨ (នៅត្រង់ ឆ៣១), ទំព័រ ១១ (នៅត្រង់ ឆ៣៥), ទំព័រ ២២ (នៅត្រង់ ឆ៤០), និងទំព័រ ២៩ (នៅត្រង់ ឆ១២៤)។

ឆ៤៨៖ តា ខ្លែង ត្រូវរាយការណ៍ទៅគណៈភូមិភាគគឺទៅតា រស់ ញឹម។

ស៖ លោកបាននិយាយពីឈ្មោះតា ហំ តើតា ហំគាត់មានតួនាទីអ្វីនៅក្នុងរបបខ្មែរក្រហម?

ឆ២៨៖ តា ហំ គាត់ជារងអគ្គសេនាធិការយោធាភូមិភាគ គឺជាអនុប្រធានរបស់តាខ្លែង។ [...]

ស៖ ពេលលោកធ្វើការនៅខាងភស្តុភារ សេដ្ឋកិច្ចរបស់យោធាភាគ តើខាងតំបន់គេត្រូវរាយការណ៍យ៉ាងដូចម្តេច?

ឆ៤៩៖ ចំពោះខាងឃុំ ខាងស្រុក គេរាយការណ៍ទៅតំបន់ ហើយចំពោះខាងទ័ព គឺត្រូវរាយការណ៍ទៅសេនាធិការ។ [...][50]

*(iii) កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទី ៣ (កម្មករសហករណ៍ និងផ្នែកដឹកជញ្ជូនភូមិភាគពាយ័ព្យ)*

31. ភស្តុតាងទី៣ ដែលមេធាវីការពារក្តី ស្នើសុំឲ្យទទួលយក គឺកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទី៣។ សាក្សីទី ៣ ត្រូវបានស្តាប់ចម្លើយដោយ [redacted] នៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៣[51] [redacted]។ [redacted]។

32. បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ សាក្សីទី ៣ ត្រូវបានគេផ្លាស់ពីក្រុងបាត់ដំបងទៅឃុំអូរដំបង។ សាក្សីទី ៣ ត្រូវបានគេចាត់តាំងទៅ "ជួយធ្វើបញ្ជីឈ្មោះប្រជាជន"។ ក្រោយមក គាត់ត្រូវបានគេផ្លាស់ទៅរៀនខាងមន្ទីរពាណិជ្ជកម្ម និងបញ្ជូនទៅធ្វើការ "ដឹកអំបិលយកទៅឲ្យប្រជាជន"។ នៅពាក់កណ្តាល/ចុងឆ្នាំ ១៩៧៦ សាក្សីទី ៣ ត្រូវបានគេចោទថាជាជនក្បត់ បន្ទាប់មកគាត់ត្រូវបានគេផ្លាស់ទៅភូមិមួយ ហើយចុងក្រោយបំផុតទៅសហករណ៍"ទៅកាប់ព្រៃនៅខាងសមរ

---

[50] ឯកសារ **E319/13.3.17**, កំណត់ហេតុស្តាប់ចម្លើយសាក្សីទី ២, ទំព័រ ៤, ៨ និង ១១ ដល់១២។

[51] ឯកសារ **E319/13.3.58** កំណត់ហេតុនៃការស្តាប់ចម្លើយ [សាក្សីទី ៣] ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៣ ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទី ៣")។

[52] [redacted]។

ភូមិមុខ"។ ក្រោយមក គាត់ត្រូវបានកម្មាភិបាលភូមិភាគនិរតី ចាត់តាំងទៅវាស់ដី ជាតួនាទីដែលគាត់នៅកាន់រហូតដល់ពេលវៀតណាមចូលមកដល់[53]។

33. នៅពេលដែលសួរថាតើហេតុអ្វីបានជាកម្មាភិបាលភូមិភាគនិរតីមកជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ គាត់បានផ្តល់ចម្លើយយ៉ាងលម្អិតអំពីភូមិភាគនានាដែលប្រឆាំងនឹងប៉ុល ពត និងការបែងចែក ប.ក.ក ទៅជាបី ឬបួនក្រុម៖

ឆ.១៣៖ គេចោទថាពួកកម្មាភិបាលមានអាឌិតទាក់ទងនឹងខ្មែរក្រហមវៀតមិញ និងមានទំនាក់ទំនងនឹងគណៈភូមិភាគបូព៌ាឈ្មោះ សោម ភឹម ហើយភូមិភាគទាំងពីរនេះគឺជាសត្រូវរបស់ប៉ុល ពត។ ទិដ្ឋភាពជាក់ស្តែង តាមការសង្កេតរបស់ខ្ញុំ ខ្មែរក្រហមមាន ៣ ទៅ៤ ក្រុម៖ ក្រុមទី ១ គឺក្រុមវៀតមិញ ក្រុមទី ២ ក្រុមខ្មែរក្រហមស្នេហាជាតិ ក្រុមទី ៣ គឺក្រុមខ្មែរក្រហមសីហនុ ហើយក្រុមទី៤ គឺក្រុមខ្មែរក្រហមមកពីចិន ដែលមានប៉ុល ពត[54]។

34. សាក្សីទី ៣ អាចផ្តល់ព័ត៌មានអំពីថ្នាក់ដឹកនាំភូមិភាគពាយ័ព្យមួយចំនួន។

ស.៖ តើលោកដឹងថា តា ហេង ទាវ មានមុខងារជាអ្វី? ហើយតើមានអ្វីកើតឡើងចំពោះគាត់ដែរឬទេ?

ឆ.១៦៖ តា ហេង ទាវ ជាអនុប្រធានភូមិភាគពាយ័ព្យផង និងក្តាប់តំបន់ ១ ផង តែ តា សាយ ជាប្រធានតំបន់ ១។ អ្នកដែលមានអំណាចជាងគេនៅក្នុងភូមិភាគនេះមានពីរនាក់គឺ តា ញឹម ហៅ តា កៅ និងតាហេង ទាវ ហៅ តាបែត។ [...] តាហេង ទាវ គាត់ នៅរស់ក្រោយឆ្នាំ ១៩៧៩ ហើយគាត់ធ្វើជារដ្ឋមន្ត្រីសហជីពជំនាន់ ហ៊ុន សែន, ហេង សំរិន, ជា ស៊ីម តែគាត់ស្លាប់ហើយ[55]។

35. សាក្សីទី ៣ បានពន្យល់ថា ទំនាក់ទំនងរវាង រស់ ញឹម និងសោម ភឹម មិនត្រឹមតែមានលក្ខណៈនយោបាយប៉ុណ្ណោះទេ ប៉ុន្តែក៏មានលក្ខណៈផ្ទាល់ខ្លួនផងដែរ៖

[53] ឯកសារ **E319/13.3.58** កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សីទី ៣ ទំព័រ ៣-៤(នៅ ឆ.២)។

[54] ឯកសារ **E319/13.3.58** កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សីទី ៣ ទំព័រ ៦ (គូសបញ្ជាក់បន្ថែម កែតម្រូវឯកសារដើម លុបឃ្លាភាសាខ្មែរ)។

[55] ឯកសារ **E319/13.3.58**, កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សីទី ៣ ទំព័រ ៦ (គូសបញ្ជាក់បន្ថែម លុបឃ្លាភាសាខ្មែរ)។

ស.៖ តើលោកដែលឮពីឈ្មោះតា ជៀល ដែរឬទេ?

ឆ.១៩៖ ខ្ញុំមិនដែលឮពីឈ្មោះនេះទេ តែ ខ្ញុំឮពីឈ្មោះឆ្នាំង គាត់គឺជាកូនប្រុសរបស់តា សោម ភឹម និងជាកូនប្រសាររបស់តា កៅ[56]។

36. ចុងក្រោយបំផុត សាក្សីទី ៣ ក៏បានផ្តល់ព័ត៌មានយ៉ាងលម្អិតទាក់ទងនឹងមេឃុំអូរដំបងរបស់គាត់ ឈ្មោះ តា លី ហៅ តា គឹម ដែលគាត់និយាយថានៅរស់ ហើយពីមុនធ្វើការជាអ្នកនាំសារឱ្យគេ រួមមាន នួន ជា ផងដែរ[57]៖

ឆ.២៖ [...] មេឃុំអូរដំបងឈ្មោះ តាលី ហៅ តាគឹម គាត់គឺជាអ្នកស្រុកភូមិនេះ កាលពីអតីតកាល គាត់ធ្លាប់ធ្វើជានិរសាររបស់តាញឹម, តាប៉ែត និងតានួន ជា ហើយសព្វថ្ងៃ គាត់នៅរស់នៅឡើយ។ តា លី គាត់ជាមនុស្សល្អណាស់ ហេតុនេះហើយបានជាគាត់អាចរស់នៅភូមិឃុំនេះបានវិញ។ [...]

ស៖ តើលោកអ្នកប្រាប់យើងបានទេថានរណាដែលនៅរស់ហើយ អាចប្រាប់យើងពីរចនាសម្ព័ន្ធដឹកនាំរបស់ភូមិភាគពាយ័ព្យ និងតំបន់បានដែរឬទេ?

ឆ.៤១៖ គឺមាន តាលី និងម្នាក់ទៀតឈ្មោះ [redacted]

[56] ឯកសារ **E319/13.3.58** កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សីទី ៣ ទំព័រ ៧ (គូសបញ្ជាក់បន្ថែម លុបឃ្លាភាសាខ្មែរ)។ នៅ ឆ. ១៦ សាក្សី បង្ហាញថា ឈ្មោះ កៅ គឺជាឈ្មោះហៅក្រៅរបស់ រស់ ញឹម៖ *សូមមើល* កថាខណ្ឌ ៣០ ខាងលើ។

[57] មេធាវីការពារក្តីកត់សម្គាល់ថា តា លី ហៅ តា គឹម គឺជាសាក្សី2-TCW-920 (ពីមុនជា TCW-406)។ មេធាវីការពារក្តីពីដើមឡើយបានស្នើនៅក្នុងបញ្ជីសាក្សីបឋមរបស់ខ្លួននៅក្នុងសំណុំរឿង 00២។ ហើយគាត់បន្ទាប់មកត្រូវបានស្នើដោយសហព្រះរាជអាជ្ញាជាសាក្សីក្នុងសំណុំរឿង 00២/0២។ [redacted] សាក្សីបានពីពណ៌នាអំពីសកម្មភាពនៅភូមិភាគពាយ័ព្យ។ ទោះបីជាយ៉ាងណាក៏ដោយមេធាវីការពារក្តីមិនបានដាក់បញ្ចូលនូវកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណើនេះ ឬ ស្នើសុំឱ្យគាត់មកផ្តល់សក្ខីកម្មពីព្រោះខ្លួនកម្រិតទៅលើតែភស្តុតាងដែលមានសារសំខាន់ពិតប្រាកដសម្រាប់បណ្តឹងសាទុក្ខរបស់ខ្លួន។ ដោយសារតែសក្ខីកម្មរបស់សាក្សី2-TCW-920 មានភាពពាក់ព័ន្ធ មេធាវីការពារក្តីពិចារណាថា សាក្សី ១ដល់ ៤ គឺមានទូលំទូលាយ និងលម្អិត ដែលទំនងជាជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត

[58] ឈ្មោះនេះហាក់ដូចបង្ហាញថាជាសាក្សី SCW-5។ ទោះយ៉ាងណា នៅក្នុងកំណត់ហេតុសក្ខីកម្មរបស់សក្ខីរូបនេះទាំងភាសាអង់គ្លេស ទាំងភាសាខ្មែរ ការសរសេរឈ្មោះគាត់មានតួអក្សរមួយខុសផ្សេងពីនេះ។

01111012



[redacted][59]។

### *(iv) កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីទី ៤ (កម្មករភូមិភាគពាយ័ព្យ)*

37. ភស្តុតាងទី៤ ដែលមេធាវីការពារក្ដី ស្នើសុំឱ្យទទួលយក គឺកំណត់ហេតុនៃការស្ដាប់ចម្លើយ សាក្សី ទី៤។ សាក្សីទី ៤ ត្រូវបានស្ដាប់ចម្លើយដោយ[redacted] នៅថ្ងៃ ទី ១៥ ខែ តុលា ឆ្នាំ ២០១៤[60] [redacted]។

38. នៅឆ្នាំ ១៩៧៥ សាក្សីទី ៤ គឺជាសិស្សវិទ្យាល័យនៅក្រុងបាត់ដំបង។ បន្ទាប់មក គាត់ត្រូវបានគេ ជម្លៀសទៅឃុំអូរម៉ាល់ នៅ តំបន់ ៣ របស់ភូមិភាគពាយ័ព្យ។ ដំបូង គាត់ធ្វើការនៅការដ្ឋានឃុំ ត្បាញក្រមា ហើយក្រោយមក ត្រូវបានគេចាត់តាំងទៅធ្វើការនៅការដ្ឋានភ្នំសំពៅ ដែលជា ការដ្ឋានតំបន់។

39. នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់ខ្លួន សាក្សីទី ៤ បានរៀបរាប់អំពីកាលៈទេសៈដែលបង្ហាញ ឱ្យឃើញពីការផ្លាស់ប្ដូរថ្នាក់ដឹកនាំភូមិភាគពាយ័ព្យដូចខាងក្រោម៖

> ឆ.១០៖ [...] ប្រហែលនៅក្នុងឆ្នាំ ១៩៧៨ ខ្ញុំឃើញឧទ្ធម្ភាគចក្រមួយហោះជុំវិញទីកន្លែងខ្ញុំធ្វើ ស្រែ ហើយបន្ទាប់មក នៅពេលល្ងាច គេបានប្រាប់ខ្ញុំថា តា ញឹម ត្រូវបានគេចាប់ខ្លួនហើយ។ ចាប់តាំងពីពេលនោះមក គឺមានការផ្លាស់ប្ដូរមេដឹកនាំនៅក្នុងតំបន់ដែលខ្ញុំរស់នៅ។

40. គាត់ក៏បានបង្ហាញអត្តសញ្ញាណថ្នាក់ដឹកនាំមួយចំនួនរបស់ភូមិភាគពាយ័ព្យ ដែលសុទ្ធតែត្រូវបាន កម្មាភិបាលភូមិភាគនិរតីចាប់ខ្លួន៖

---

[59] ឯកសារ E319/13.3.58 កំណត់ហេតុនៃការស្ដាប់ចម្លើយ សាក្សីទី ៣ ទំព័រ ១១ ដល់១២។

[60] ឯកសារ E319/19.3.198 'កំណត់ហេតុនៃការស្ដាប់ចម្លើយ [សាក្សីទី ៤]' ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១៣ ("កំណត់ហេតុនៃ ការស្ដាប់ចម្លើយសាក្សីទី ៤")។

[61] [redacted]។

*ឆ.៨៖ តំបន់ ៣ ដែលគ្រប់គ្រងដោយតា ឆាំ។ តា ហឿន គឺជាគណៈស្រុក ប៉ុន្តែ ខ្ញុំមិនដឹងថាគាត់ជាគណៈស្រុកណាទេ។ តា សុខ (ឈ្មោះដើម៖ ពុំ) ជាគណៈឃុំអូរម៉ាល់។*

ឆ.៩៖ តំបន់ ៣ ស្ថិតនៅក្នុងភូមិភាគពាយ័ព្យ ដែលគ្រប់គ្រងដោយ រស់ ញឹម ហៅ មូល សម្បត្តិ។

ស៖ តើថ្នាក់ដឹកនាំដែលលោកបានរៀបរាប់ខាងលើនៅធ្វើការរហូតដល់ចុងរបបខ្មែរក្រហមដែរឬទេ?

ឆ.១០៖ ពួកគេមិនគ្រប់គ្រងនៅទីនោះរហូតដល់ចុងរបបខ្មែរក្រហមនោះទេ[62]។

41. សាក្សីទី ៤ ក៏បានរៀបរាប់អំពីទំនាក់ទំនងរវាងកម្មាភិបាលភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ដែលនាំឲ្យមានការចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យ៖

ឆ. តើកម្មាភិបាលថ្មីដែលមកគ្រប់គ្រងទីនោះមកពីកន្លែងណាដែរ?

ឆ.១១៖ ពួកគេមកពីភូមិភាគនិរតី។ ដំបូង ពួកកម្មាភិបាលថ្មីដែមកពីនិរតីមកធ្វើការជាមួយកម្មាភិបាលចាស់ពាយ័ព្យសិន តែក្រោយមកទើបគេផ្លាស់កម្មាភិបាលចាស់ចេញ។ [...]

ឆ.២៥៖[...] ខ្ញុំបានឮគេនិយាយថា នៅក្រោយការមកដល់របស់ពួកនិរតីប្រហែលជាចុងឆ្នាំ ១៩៧៧ ដើមឆ្នាំ ១៩៧៨ នៅពេលនោះពួកកម្មាភិបាលភាគពាយ័ព្យ មិនទាន់ត្រូវបានគេដកចេញទាំងស្រុងទេ គឺនៅធ្វើការចម្រុះគ្នានៅឡើយ។

## ខ. សាក្សីបីនាក់ដែលការស្តាប់ចម្លើយពួកគាត់បានចុះផ្សាយនៅក្នុងសៀវភៅ *នៅក្រោយវាលពិឃាត* *(Behind the Killing Fields)*

42. សាក្សីទី ៣ ទី ៤ និង ៥ ដែលមេធាវីការពារក្តី ស្នើអង្គជំនុំជម្រះតុលាការកំពូល កោះហៅឲ្យមកផ្តល់សក្ខីកម្ម គឺ 2-TCW-959, 2-TCW-960 និង2-TCW-961។ មេធាវីការពារក្តី បានប្រើប្រាស់កថាខណ្ឌ ២០ នៃសំណើលើកទីបីសុំទទួលយកភ័ស្តុតាង ដើម្បីរៀបរាប់អំពីសក្តានុពលសក្ខីកម្មរបស់សាក្សីទាំងនេះ[63]។ បន្ថែមពីលើនេះ មេធាវីការពារក្តីកត់សម្គាល់ឃើញថា នៅខែ កក្កដា ឆ្នាំ ២០១៤ ហើយក៏បានស្នើរួចហើយសុំទទួលយកសាក្សីទាំងបីរូប ជាសាក្សីនៅក្នុងសំណុំ

---

[62] ឯកសារ **E319/19.3.198** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទី ៤ ទំព័រ ៤ (គូសបញ្ជាក់បន្ថែម លុបឃ្លាភាសាខ្មែរ)។

[63] ឯកសារ **F2/4** សំណើលើកទីបីសុំបន្ថែមភ័ស្តុតាង កថាខណ្ឌ ២០។

រឿង ០០២/០២។ គ្មានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងនេះធ្លាប់បានផ្តល់សក្ខីកម្មនៅ អ.វ.ត.ក ទេ[64] ហើយបើតាមមេធាវីការពារក្តីបានដឹង ក៏មិនធ្លាប់ត្រូវបាន ក.ស.ច.ស ស្តាប់ចម្លើយដែរ។ ទោះយ៉ាងណា គាត់ត្រូវបានសម្ភាសដោយ ថេត សម្បត្តិ(ប្រហែលជាមួយ Rob Lemkin)។ សេចក្តីសង្ខេងអំពីកិច្ចសម្ភាសន៍របស់សាក្សីទាំងបីរូប មានចុះផ្សាយនៅក្នុងសៀវភៅរបស់ ថេត សម្បត្តិ ចំណងជើង *នៅក្រោយវាលពិឃាត* ដែលសៀវភៅទាំងមូលមាននៅក្នុងសំណុំរឿងរួចហើយ និងបានបោះពុម្ពនៅឆ្នាំ ២០១០[65]។

*(i)* ***2-TCW-959 (ប្រធានមន្ទីរពេទ្យសម័យកម្ពុជាប្រជាធិបតេយ្យនៅបាត់ដំបង)***

43. សេចក្តីសង្ខេបរបស់ ថេត សម្បត្តិ អំពីកិច្ចសម្ភាសន៍របស់គាត់ជាមួយ 2-TCW-959 មានដូចខាង ក្រោម ៖

> [2-TCW-959] ប្រធានពេទ្យតំបន់ក្នុងខេត្តបាត់ដំបង បាននិយាយនៅក្នុងបទសម្ភាសន៍ថា នៅក្នុងកិច្ចប្រជុំមួយដែលគាត់បានចូលរួមនៅស្ពៅ ដើម្បីផ្តលប៉ុល ពត រស់ ញឹម និយាយថា ការរក្សាការសម្ងាត់គឺសំខាន់ណាស់ព្រោះអ្នកដែលរកឃើញថាចូលរួមក្នុងផែនការនេះច្បាស់ជាត្រូវសម្លាប់ចោលជាមិនខាន។ [2-TCW-959] និយយាថា បន្ទាប់ពីទទួល ការណែនាំពីរស់ ញឹម គាត់បញ្ជាឲ្យទាហាន ៧០ នាក់ទៅដឹកជញ្ជូនថ្នាំ និង សម្ភារៈ វេជ្ជសាស្ត្រទៅដាក់នៅទីបញ្ជាការកលពលរបស់គាត់។ នៅពេលសួរពីមូលហេតុក្នុងការដឹកជញ្ជូននេះ គាត់ក៏កុហកថាត្រៀមធ្វើសង្គ្រាមជាមួយថៃ។ ពួកគេបានរក្សាទុកអង្ករ នៅតាមរោងម៉ាស៊ីន និងបានលាក់ទុកប្រេងសាំងនៅតាមតំបន់ជាច្រើនក្នុងខេត្តបាត់ដំបង។ ពួកគេមានផែនការបំផ្លាញស្ពានឆ្លងស្ទឹងសង្កែក្នុងខេត្តបាត់ដំបងដើម្បីគ្រប់គ្រងប៉ែកខាងលិចស្ទឹងដែលនៅទីនេះមានការស្តុកទុកសម្ភារៈ ស្បៀង និងបរិក្ខាផ្សេងទៀត។ [2-TCW-959] បាននិយាយថា 'នេះគឺជាផែនការដ៏ធំ និងសំខាន់មួយ

---

[64] ឯកសារ **E307/4** 'បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មីសម្រាប់សំណុំរឿង ០០២/០២' ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។ ឯកសារ **E307/4.2** 'ឧបសម្ព័ន្ធ ក-បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មី សម្រាប់សំណុំរឿង ០០២/០២' ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។ ឯកសារ **E307/4.3** 'ឧបសម្ព័ន្ធ ខ-បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មីសម្រាប់សំណុំរឿង ០០២/០២' ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។

[65] ឯកសារ **E3/4202** Gina Chon និងថេត សម្បត្តិ សៀវភៅចំណង នៅក្រោយវាលពិឃាត៖ មេដឹកនាំមួយរូបរបស់ខ្មែរក្រហម និងជនរងគ្រោះម្នាក់ (Behind the Killing Fields: A Khmer Rouge Leader and One of his Victims) ("នៅក្រោយវាលពិឃាត") ERN 00757532 [redacted]។

ហើយបើ ទទួលបានជ័យជម្នះ អ្វីៗសព្វយ៉ាងនឹងមានភាពល្អឡើងវិញ។ ពួកយើងទទួលបានការ លើកទឹកចិត្តឱ្យចូលរួមអនុវត្តផែនការនេះ ព្រោះសមាជិកមួយចំនួននៅមជ្ឈិមមកពីភ្នំពេញដូចជា វន វេត និង សោ ភឹម នៅភូមិភាគបូព៌ា ក៏គាំទ្រផែនការនេះដែរ"[66] ។

*(ii) 2-TCW-960 (អតីតមេបញ្ជាការកងពលភូមិភាគពាយ័ព្យ)*

44. សេចក្ដីសង្ខេបរបស់ ថេត សម្បត្តិ អំពីកិច្ចសម្ភាសន៍របស់គាត់ជាមួយ 2-TCW-960 មានដូចខាងក្រោម៖

រស់ ញឹម បានឱ្យ [2-TCW-960] មេបញ្ជាការកងពល ទៅទាក់ទងពួកកុម្មុយនីស្ដថៃដែលនឹងទុកស្រូវ ត្រីងៀត និងអាវុធសម្រាប់ខ្លួនរហូតដល់ពេលវាយប្រហារ។ គេបានដឹកជញ្ជូនសម្ភារៈទាំងនោះទៅថៃនៅពេលយប់។ ថែល ឈឿន បាននិយាយនៅក្នុងបទសម្ភាសន៍ថា 'ខ្ញុំសោកស្ដាយណាស់ផែនការយើងមិនបានជោគជ័យ។ នៅពេលខ្ញុំជាប់ឃុំនៅកន្លែងកសាង ខ្ញុំគិតថាពួកយើងគួរតែបានវាយប្រហារមុន។ ខ្ញុំស៊ូស្លាប់ក្នុងសមរភូមិឱ្យតែបានអនុវត្តផែនការនេះប្រសើរជាងនៅកន្លែងនេះ"[67]។

45. មេធាវីការពារក្ដីបានកត់សម្គាល់បន្ថែមទៀតថា មានឯកសារពីរដែលមានស្រាប់នៅក្នុងសំណុំរឿងដែលយោងទៅបុគ្គលម្នាក់ហាក់ដូចជា 2-TCW-961ដែល ជាបុគ្គលដែលមានឈ្មោះដូចគ្នា និងបទពិសោធន៍ដូចគ្នានៅភូមិភាគពាយ័ព្យ[68]។

---

[66] ឯកសារ **E3/4202** Gina Chon និងថេត សម្បត្តិ សៀវភៅចំណង នៅក្រោយវាលពិឃាត ERN 00757532 [redacted] ERN 00858343 ទំព័រ ១៣០ ភាសាខ្មែរ (គូសបញ្ជាក់បន្ថែម)។

[67] ឯកសារ **E3/4202**, Gina Chon និង ថេត សម្បត្តិ នៅក្រោយវាលពិឃាត ERN 00757532 (ទំព័រ ១០៦-៧ ភាសាអង់គ្លេស), ERN 00858343 ទំព័រ ១៣០ ភាសាខ្មែរ) (គូសបញ្ជាក់បន្ថែម)។

[68] សូមមើលឯកសារ E3/1894 "បញ្ជីឈ្មោះជនក្បត់ដែលត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយរបស់ សៀប ប៉ូយ ហៅ ស៊ាន" នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៧ ERNs 00702087-8 "[មានឈ្មោះដូច TCW-961] នៅឆ្នាំ ៧២ បានក្លាយជាប្រធានកងអនុសេនាធំដឹកជញ្ជូន...រហូតដល់ដើមឆ្នាំ១៩៧៣ [មានឈ្មោះដូច TCW-961] ក៏ត្រូវបានចាត់តាំងឡើងដោយ ស៊ូ ជាមេបញ្ជាការវរសេនាតូចរបស់តំបន់ ៤ [...] សម្រាប់ រឿន ចិត្រ សំ ឡៃ និង[មានឈ្មោះដូច TCW-961] ពួកគេបានចាត់តាំងនៅតាមបណ្ដោយផ្លូវជាតិលេខ៥" ។ E3/3849 ការឆ្លើយតបរបស់ ទិត សុន ហៅ ញ៉ែម ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៧ ERN 00836005 "គាត់និយាយថា នៅពេលអង្គការដកគាត់ចេញពីកំពង់សោម បង [មានឈ្មោះដូច TCW-961] និងគាត់ត្រូវបានបញ្ជាឱ្យបើក

*(iii) 2-TCW-961 (អតីតកម្មាភិបាលភូមិភាគពាយព្យមកពីពោធិ៍សាត់)*

46. សេចក្តីសង្ខេបរបស់ ថេត សម្បត្តិ អំពីកិច្ចសម្ភាសន៍របស់គាត់ជាមួយ 2-TCW-961 មានដូចខាងក្រោម៖

កម្មាភិបាលខ្មែរក្រហមម្នាក់ដែលនៅរស់រានមានជីវិត បានឱ្យដឹងថា ពិតជាមានផែនការទម្លាក់ប៉ុល ពត, នួន ជា និងមេដឹកនាំដទៃទៀត។ អ៊ិន ធឿន ដែលរស់នៅក្នុងខេត្តពោធិ៍សាត់ និយាយថា ក្នុងឆ្នាំ ១៩៧៦ មានផែនការធ្វើរដ្ឋប្រហារដែលនឹងដឹកនាំដោយភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា។ គាត់បាននិយាយថា កម្មាភិបាលក្នុងតំបន់នោះជាញឹកញាប់ប្រជុំនៅឃុំស្ពៅ។ ផែនការបានរៀបចំឱ្យកម្មាភិបាលភូមិភាគពាយ័ព្យដណ្តើមយកខេត្តបាត់ដំបង បន្ទាប់មក ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងទីក្រុងភ្នំពេញ។ ក្នុងពេលជាមួយគ្នាដែរ ភូមិភាគបូព៌ា នឹងវាយប្រហារចាប់ពីបណ្តាតំបន់នៅភាគខាងកើតទីក្រុងភ្នំពេញ។ អ៊ិន ធឿន និយាយថា "អ្នកណាក៏ដឹងពីផែនការផ្តួលរំលំការដឹកនាំរបស់ ប៉ុល ពត"។ ពួកគេបានពិភាក្សាអំពីការសេរីនិយម និងការរៀបចំឡើងវិញនូវអ្វីៗដែលប៉ុល ពត បានបង្កើតឡើង។ ដោយមានការទទួលស្គាល់ថា គោលដៅរបស់អង្គការមានភាពជ្រុលនិយមហួសហេតុ និងមិនគ្មានភាពជាក់ស្តែងនោះ កម្មាភិបាលដែលមានបំណងចង់ផ្តួលរំលំ ប៉ុល ពត គិតថា កម្ពុជា ចាំបាច់ត្រូវធ្វើដំណើរទៅមុខដោយសន្សឹមៗ និងធ្វើកំណែទម្រង់ជាដំណាក់កាលៗ ចៀសវាងការសម្រុកទៅដោយតក់ក្រហល់បណ្តាលឱ្យមានការសម្លាប់ប្រជាជន[69]។

## គ. កំណត់ហេតុនៃការស្តាប់ចម្លើយទី២ របស់សាក្សី SCW-5 និងឧបសម្ព័ន្ធ

47. ភស្តុតាងទី ៥ និងទី ៦ ដែលមេធាវីការពារក្តី ស្នើសុំដាក់គឺកំណត់ហេតុនៃការស្តាប់ចម្លើយទី២ របស់សាក្សី SCW-5 រួមជាមួយនឹងឧបសម្ព័ន្ធភ្ជាប់ជាមួយកំណត់ហេតុនេះ។ [redacted]។ សំណើលើកទីបីសុំទទួលយកភស្តុតាង បានស្នើសុំទទួល

---

ច្រកទ្វាពាណិជ្ជកម្មនៅប៉ោយប៉ែត និង អូរជ្រៅ។ គាត់និង [មានឈ្មោះដូច TCW-961] ឆ្លៀតឱកាសចាត់តាំង ប៊ាន ជាប្រធានច្រកដើម្បីទាក់ទងខ្សែក្បត់នៅប្រទេសថៃ" (បញ្ជាក់បន្ថែម ឃ្លាខ្មែរបានលុប)។

[69] ឯកសារ **E3/4202** Gina Chon និង ថេត សម្បត្តិ នៅក្រោយវាលពិឃាត ERN 00757531(ទំព័រ ១០៤-៥ ភាសាអង់គ្លេស), ERN 00858339-40 (ទំព័រ ១២៦-២៧ ភាសាខ្មែរ) (គូសបញ្ជាក់បន្ថែម)។

យកកំណត់ហេតុមួយក្នុងចំណោមកំណត់ហេតុទាំងពីរនេះ[70]។ កំណត់ហេតុនៃការស្ដាប់ចម្លើយទី ២ របស់សាក្សី SCW-5 គឺទាក់ទងនឹងកម្រងរូបថតចំនួន ២៧ សន្លឹកដែលភរិយារបស់សាក្សី SCW-5 [redacted]។ កំណត់ហេតុនៃការស្ដាប់ចម្លើយនេះបានធ្វើឡើងនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣[71] ហើយរូបថតទាំងនោះមានភ្ជាប់ជាឧបសម្ព័ន្ធជាមួយនឹងកំណត់ហេតុនេះ[72]។ [redacted]។

48. កំណត់ហេតុនៃការស្ដាប់ចម្លើយទី២ របស់សាក្សី SCW-5 បង្ហាញពីមតិយោបល់របស់គាត់ស្ដីពីកម្រងរូបថតទាំង ២៧ សន្លឹក។ សាក្សី SCW-5 បានពន្យល់ថា គាត់បានថតចម្លងរូបថតទាំងនេះពីមនុស្សម្នាក់ឈ្មោះ ប៉ាត់ ថៃ ដែលត្រូវបានគេរាយការណ៍ថាជាលេខារបស់ វស់ ញឹម ហើយទទួលខុសត្រូវខាងព័ត៌មាន។ បន្ទាប់ពីឆ្នាំ ១៩៧៩ គាត់ធ្វើការនៅក្រសួងមហាផ្ទៃ។ ប៉ាត់ ថៃ មាន “រូបថតច្រើនណាស់ប្រហែលជាមួយវ៉ាលី” ហើយប្រហែលជាគាត់អាចឲ្យរូបថតទាំងអស់នៅទៅមជ្ឈមណ្ឌលឯកសារកម្ពុជា[74]។ ក្នុងចំណោមរូបថតទាំងនោះ រូបថតគួរឲ្យចាប់អារម្មណ៍រួមមានរូបថតមួយសន្លឹកដែលសាក្សី SCW-5 និយាយថា អាចជារូបថតរបស់ វស់ ញឹម[75] និងរូបថតមួយសន្លឹកទៀតបង្ហាញពីទិដ្ឋភាពមួយដែលសាក្សី SCW-5 និយាយថាអាចថតនៅពោធិ៍សាត់“ក្រោយបែករបបលន់ នល់ក្នុងឆ្នាំ១៩៧៥”[76]។

## III. ច្បាប់ជាធរមាន

[70] ឯកសារ **E319.1.27** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី SCW-5 ទី១។

[71] ឯកសារ **E319.1.28** ‘កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [SCW-5]’ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ (“កំណត់ហេតុនៃការស្ដាប់ចម្លើយ SCW-5 ទីពីរ”)។

[72] ឯកសារ **E319.1.28.1** ‘ឧបសម្ព័ន្ធនៃចម្លើយរបស់សក្សី [SCW-5]’ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ (“ឧបសម្ព័ន្ធ រូបថត”)។

[73] [redacted]

[74] ឯកសារ **E319.1.28** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី SCW-5 ទី ២ ទំព័រ ៣-៤ (នៅ ឆ. ៣ និង ឆ.៥)។

[75] ឯកសារ **E319.1.28** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី SCW-5 ទី ២ ទំព័រ ៧ (នៅ ឆ. ២៧)។ *សូមមើលផងដែរ* ឯកសារ **E319.1.28.1**, ឧបសម្ព័ន្ធ រូបថត ERN 00968058(រូបថតលេខ ១៦)។

[76] ឯកសារ **E319.1.28** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី SCW-5 ទី ២ ទំព័រ ៧ (នៅ ឆ. ៣២)។ *សូមមើលផងដែរ* ឯកសារ **E319.1.28.1**, ឧបសម្ព័ន្ធ រូបថត ERN 00968058 (រូបថតលេខ ២១)។

49. នៅក្នុងក្របខ័ណ្ឌ អ.វ.ត.ក ការទទួលយកភ័ស្តុតាងថ្មីនៅពេលប្តឹងសាទុក្ខ មានចែងនៅក្នុងវិធានផ្ទៃក្នុង ១០៤(១) និង ១០៨(៧) របស់ អ.វ.ត.ក។ អនុលោមតាមវិធានផ្ទៃក្នុង ១០៤(១) អង្គជំនុំជម្រះតុលាការកំពូល "អាចបើកការពិនិត្យលើភ័ស្តុតាង និងស្វែងរកភ័ស្តុតាងថ្មី" ដើម្បីធ្វើការសម្រេចលើបណ្តឹងសាទុក្ខ។ វិធាន ១០៨(៧) ចែងពីផ្នែកពាក់ព័ន្ធដូចខាងក្រោម៖

> ភាគីអាចស្នើសុំបន្ថែមភ័ស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) បើសិនជាភ័ស្តុតាងនោះ មិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តីស្នើសុំបន្ថែមភ័ស្តុតាងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនង ដោយផ្ទាល់រវាងភ័ស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសំអាងហេតុជាក់លាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក។ ភាគីផ្សេងទៀតដែលរងការប៉ះពាល់ដោយសេចក្តីស្នើសុំនេះ អាចធ្វើការឆ្លើយតបក្នុងរយៈពេល១៥ថ្ងៃ ចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីស្នើសុំនោះ។

50. អង្គជំនុំជម្រះធ្លាប់បានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីទទួលយកភស្តុតាងថ្មីអនុលោមតាមវិធាន ១០៤(១) និង ១០៨(៧) ទាក់ទងនឹងបណ្តឹងសាទុក្ខ និងអនុលោមតាមវិធាន ១០៨(៧) ទាក់ទងនឹងបណ្តឹងសាទុក្ខដែលបានដាក់ប្រឆាំងនឹងសាលក្រម នៅក្នុងសំណុំរឿង ០០១[77]។

## IV. ឧឡឹករណ៍

### ក. ការរក្សាសម្ងាត់ និងលក្ខខណ្ឌនៃការដាក់បង្ហាញ

51. មេធាវីការពារក្តីទទួលស្គាល់លក្ខខណ្ឌនៃការដាក់បង្ហាញ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមរយៈសហព្រះរាជអាជ្ញាអន្តរជាតិ បានកំណត់លើក្រុមមេធាវីការពារក្តីទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៣ និង ០០៤ ព្រមទាំងលក្ខខណ្ឌបន្ថែម

---

[77] ឯកសារ **F2/5** អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចទាក់ទងនឹងសាក្សី កថាខណ្ឌ ១៩-២៦។ សំណុំរឿង ០០១/១៨-កក្កដា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក *សហព្រះរាជអាជ្ញាតទល់នឹងកាំង ហ្គេកអ៊ាវ* ឯកសារ **F2/5/1** 'សេចក្តីសម្រេចលើសំណើបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ សុំដាក់ភ័ស្តុតាងបន្ថែម' ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១ ERNs 00657393-00657394។ សំណុំរឿង ០០១/១៨-កក្កដា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក *សហព្រះរាជអាជ្ញាតទល់នឹងកាំង ហ្គេកអ៊ាវ* ឯកសារ **F2/4** 'សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ និងតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១,២ និង ៣ សុំដាក់ភ័ស្តុតាងបន្ថែម' ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ERNs 00656521-00656523។

ដែលអង្គជំនុំជម្រះបានកំណត់លើករណីនេះ[78]។ សំណើសុំបច្ចុប្បន្ននេះត្រូវបានស្នើឡើងដាក់ជាឯកសារសម្ងាត់ [redacted]។ [redacted]។ មេធាវីការពារក្តីបានស្នើសុំដូច្នេះដើម្បីបង្ហាញជូនអង្គជំនុំជម្រះតុលាការកំពូលឱ្យបានពេញលេញអំពីសាវតារនីតិវិធី និងស្ថានភាពដែលប្រឈមចំពោះមុខមេធាវីការពារក្តី និងព្រមទាំងអង្គជំនុំជម្រះផងដែរ។ មេធាវីការពារក្តីយល់ឃើញថា ឯកសារយោងបែបនេះអាចទទួលយកបានតាមរយៈការដាក់ឯកសារសម្ងាត់ ហើយនឹងផ្តល់សំណើសុំនេះជូនអង្គជំនុំជម្រះក្នុងទម្រង់ជាសំណៅសាធារណៈដែលមានការកោសលុប។

## ខ. សំអាងហេតុនៃអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភ័ស្តុតាងបន្ថែមទាំងនេះ

52. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងសាលក្រមថា រស់ ញឹម បានចេញបញ្ជាឱ្យកាប់សម្លាប់ទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទៅឱ្យកម្មាភិបាលស៊ីវិល និងយោធានៅថ្នាក់តំបន់ប៉ុន្មានថ្ងៃក្រោយរំដោះខេត្តពោធិ៍សាត់[79]។ អង្គជំនុំជម្រះបានរកឃើញថា បញ្ជានេះត្រូវបានអនុវត្តនៅទីរួមខេត្តពោធិ៍សាត់ និងនៅទួលពោធិ៍ជ្រៃ[80]។ អង្គជំនុំជម្រះក៏បានរកឃើញផងដែរទៀតថា បញ្ជានេះគឺជាការអនុវត្តគោលនយោបាយនៃសហឧក្រិដ្ឋកម្មរួមដែលបានអនុវត្តដោយ រស់ ញឹម និង នួន ជា ក្នុងចំណោមកម្មាភិបាលផ្សេងទៀត ដើម្បី "កំណត់គោលដៅលើការចាប់ខ្លួន ការកាប់សម្លាប់ និង/ការបាត់ខ្លួន" អតីតសមាសភាពទាំងអស់នៃរបបសាធារណរដ្ឋខ្មែរ[81]។

53. អង្គជំនុំជម្រះក៏បានសម្រេចផងដែរថា យោងតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ៖

> សេចក្តីសម្រេចទាំងឡាយរបស់ [ប.ក.ក] ត្រូវធ្វើឡើងដោយថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជា ដែលស្ថាប័ននេះទទួលសេចក្តីរាយការណ៍ផ្សេងៗពីថ្នាក់ក្រោម និងផ្តល់ការណែនាំទៅថ្នាក់ក្រោម

---

[78] ឯកសារ F22 "សេចក្តីណែនាំពាក់ព័ន្ធនឹងសាក្សីនានាដែលភាគីបានស្នើឡើងនៅក្នុងកិច្ចដំណើរការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥។

[79] ឯកសារ E313 សាលក្រមកថាខណ្ឌ ៦៦៧ ដល់ ៦៨១ និង ៦៨៦។

[80] ឯកសារ E313 សាលក្រមកថាខណ្ឌ ៦៦៣។

[81] ឯកសារ E313 សាលក្រមកថាខណ្ឌ ១១៩ ដល់ ១២៧, ៨១៤ និង ៨២៩។

ផងដែរ។ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធដឹកនាំដែលមានទម្រង់ជាពីរ៉ាមីតរបស់បក្ស ដោយមានអំណាចប្រមូលផ្តុំនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍តូចមួយ ដែលគ្រប់ជាន់ថ្នាក់ទាំងអស់ផ្សេងទៀតដំណើរការ នៅពីក្រោមគណៈកម្មាធិការនេះ[82]។

អង្គជំនុំជម្រះបានផ្អែកសំអាងហេតុនេះតែទៅលើការវិភាគរបស់ខ្លួនអំពីលក្ខន្តិកៈ ប.ក.ក[83] ពុំមែនភ័ស្តុតាងជាច្រើនដែលបង្ហាញអំពីមុខងារជាក់ស្តែងនៅក្នុង ប.ក.ក នោះទេ។

54. អង្គជំនុំជម្រះក៏បានរកឃើញសំអាងហេតុជាក់លាក់មួយផងដែរ អំពីតួនាទីរបស់ភូមិភាគនានានៃ ប.ក.ក ក្នុងបរិបទនៃការអនុវត្តគោលនយោបាយ ប.ក.ក ក្នុងការកំណត់គោលដៅលើទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ។ អង្គជំនុំជម្រះបានសម្រេចថា៖

ទោះបីជាទទួលស្គាល់ថា ភូមិភាគបានអនុវត្តគោលនយោបាយរបស់បក្សទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន និងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា ភូមិភាគទាំងនោះមិនមែនអនុវត្តដោយឯករាជ្យនោះឡើយ ហើយមជ្ឈិមបក្ស រួមទាំង នួន ជា ផង បានពឹងផ្អែកទៅលើភូមិភាគនានា ដែលលេខាភូមិភាគទាំងនោះ ជាធម្មតាគឺជាសមាជិកគណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍ និងផ្អែកតាមរចនាសម្ព័ន្ធឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការធ្វើឱ្យគោលនយោបាយ និងសេចក្តីសម្រេចនានារបស់បក្សកុម្មុយនីស្តកម្ពុជាមានប្រសិទ្ធភាព។ ចំណុចនេះគឺស្របទៅនឹងបទប្បញ្ញត្តិនៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា និងក៏ជាតថភាពជាក់ស្តែងផងដែរ[84]។

ជាថ្មីម្តងទៀត ការវិភាគនេះបានសំអាងលើការវិភាគតឹងរ៉ឹងដោយផ្អែកលើបទប្បញ្ញត្តិនៃលក្ខន្តិកៈ ប.ក.ក និងការទទួលខុសត្រូវផ្លូវការនៃគណៈកម្មាធិការមជ្ឈិម[85]។

## គ. សារសំខាន់នៃភ័ស្តុតាងបន្ថែម

***(i) កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួនបួនរូបពី[redacted] និងសាក្សីចំនួនបីរូបដែលកិច្ចសម្ភាសន៍របស់ពួកគេត្រូវបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅចំណងជើងថានៅពីក្រោយវាលពិឃាត***

---

[82] ឯកសារ E313 សាលក្រម កថាខណ្ឌ ២២៣ (លេខយោងជើងទំព័រត្រូវបានលុបចោល គូសបញ្ជាក់បន្ថែម)។

[83] ឯកសារ E313 សាលក្រម លេខយោងជើងទំព័រ ៧០៧ និង ៧០៨។

[84] ឯកសារ E313 សាលក្រម កថាខណ្ឌ ៨៥៩ (គូសបញ្ជាក់បន្ថែម)។

[85] ឯកសារ E313 សាលក្រម លេខយោងជើងទំព័រ ២៧២៦ និង ២៧២៧។

55. កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួនបួនដំបូងពី [redacted] ដែលមេធាវីការពារក្តីស្នើសុំឲ្យទទួលយកនៅក្នុងសំណើសុំនេះ និងសក្ខីកម្មរបស់សាក្សីចំនួនបីរូបផ្សេងទៀតដែលលើកឡើងនៅក្នុងសៀវភៅចំណងជើងថា *នៅពីក្រោយវាលពិឃាត* ពិតជាមានសារសំខាន់ចំពោះបណ្តឹងសាទុក្ខរបស់ខ្លួនយ៉ាងពិតប្រាកដ។ ភស្តុតាងរបស់សាក្សីទី ១-៣, 2-TCW-959, 2-TCW-960 និង 2-TCW-961 ជំទាស់ដោយត្រង់ៗតែម្តងនឹងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងថា ភូមិភាគពុំបានធ្វើសកម្មភាពដោយឯករាជ្យ។ ផ្ទុយទៅវិញ ភូមិភាគស្ថិតនៅពីក្រោយមជ្ឈិមបក្ស និងជាផ្នែកមួយនៃបក្សដែលមានឋានានុក្រមតឹងរ៉ឹង និងរួមមួយ។ សាក្សីទាំងនេះបញ្ជាក់ថា ប.ក.ក ត្រូវបានបែងចែកទៅជាក្រុម ដែលប្រណាំងប្រជែងគ្នាយ៉ាងជូចត់ដោយក្នុងនោះភូមិភាគពាយ័ព្យបានរួបរួមគ្នាជាមួយនឹងសមភាគីរបស់ពួកគេនៅភូមិភាគបូព៌ា និងភូមិភាគផ្សេងទៀត។ សាក្សីទី ៣ បានរៀបរាប់បន្ថែមអំពីក្រុមទាំងនេះ ដោយបានពន្យល់ថា ភូមិភាគពាយ័ព្យដែលនៅក្រោម រស់ ញឹម ត្រូវបានចោទថាជាប់និន្នាការ "ជាមួយនឹងខ្មែរវៀតមិញ" ហើយសាក្សីរូបនេះបានលើកឡើងថា ក្រុមចំនួនបួននេះត្រូវបានបែងចែកដូចខាងក្រោម៖ (១) វៀតមិញ (២) ខ្មែរក្រហមស្នេហាជាតិ (៣) ខ្មែរក្រហមខាងសីហនុ និង (៤) ខ្មែរក្រហមមកពីប្រទេសចិន (រួមទាំង ប៉ុល ពត ផងដែរ)[86]។ សាក្សី 2-TCW-959 បានពន្យល់ថាតើផែនការរបស់ រស់ ញឹម បានគាំទ្រ សោ ភឹម នៅក្នុងភូមិភាគបូព៌ា និង វន វេត នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍យ៉ាងដូចម្តេច[87]។ សក្ខីកម្មរបស់សាក្សីទី ១ ២ ៣ 2-TCW-959 និង 2-TCW-961 ស៊ីសង្វាក់គ្នាយ៉ាងជាក់លាក់ជាមួយនឹងការរៀបរាប់របស់សាក្សី SCW-5[88] និងសាក្សីមួយចំនួនផ្សេងទៀត រួមទាំង Rob Lemkin និង ថេត សម្បត្តិ ដែលបានលើកឡើងថា កម្មាភិបាលដឹកនាំនៅក្នុងភូមិភាគពាយ័ព្យ និងបូព៌ាបានបង្កើតក្រុមមួយរួមគ្នាប្រឆាំង ប៉ុល ពត ដោយបានលើកឡើងព័ត៌មានលម្អិតសំខាន់បំពេញបន្ថែមលើការរៀបរាប់របស់គាត់។

56. ជាពិសេស សាក្សីទី ១ សាក្សីទី ២ 2-TCW-959 2-TCW-960 និង 2-TCW-961 អាចមានលទ្ធភាពផ្តល់ឧទាហរណ៍ជាក់លាក់អំពីវិធានការយ៉ាងសកម្ម ដែលបានធ្វើឡើងចំពោះការបះបោរ និង/ឬ ការក្បត់ជាតិនៅក្នុងភូមិភាគឧត្តរ។ សាក្សីទី ១ បានរៀបរាប់អំពីហេតុការណ៍ដែលគាត់

[86] *សូមមើល* កថាខណ្ឌ ៣៣ ខាងលើ។

[87] *សូមមើល* កថាខណ្ឌ ៤៣ ខាងលើ។

[88] *សូមមើល ឧ.* ឯកសារ E319.1.27 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី SCW-5 លើកទីមួយ ទំព័រ ១១ (ត្រង់ ឆ.៣៥) ទំព័រ ១៣ (ត្រង់ ឆ.៤១) ទំព័រ ២៨ (ត្រង់ ឆ.១២០) ទំព័រ ២៩ (ត្រង់ ឆ.១២៤)។

បានឃើញផ្ទាល់ភ្នែកនៅពេលគាត់ធ្វើដំណើរអម រស់ ញឹម ទៅកាន់ព្រំដែនជាប់វៀតណាមដើម្បី ប្រមូលឯកសណ្ឋានយោធាពីវៀតណាម[89]។ ចំណែកសាក្សីទី ២ បានពន្យល់ថា ផែនការរបស់ កងពលយោធាទាំងពីរនៅភូមិភាគពាយ័ព្យដើម្បី "វាយបកប្រឆាំងនឹង ប៉ុល ពត" ត្រូវបានលេច ឮ"តាមរយៈគេញមួយចំនួនរបស់មជ្ឈិម" ហើយកម្មាភិបាលភូមិភាគពាយ័ព្យ តា ហំ ត្រូវបាន ចាប់ខ្លួនដោយសារគាត់ "ត្រូវបានគេចោទថាបានដឹកសម្ភារៈយោធាទៅភ្នំវាយចាប[90]។ គាត់ក៏ បានលើកឡើងអំពីវិធីដែលកម្មាភិបាលភូមិភាគពាយ័ព្យមួយចំនួនរត់ចូលព្រៃ និងបង្កើត "ចលនា ខ្មែរស"[91]។ សាក្សី 2-TCW-959 និង 2-TCW-960 បាននិយាយអំពីគំនរលាក់ទុកថ្នាំ ឧបករណ៍ ពេទ្យ អង្ករ ត្រីងៀត និងអាវុធដើម្បីត្រៀមវាយប្រហារ[92] ចំណែកសាក្សី 2-TCW-960 និង 2-TCW-961 បានពិពណ៌នាដោយឡែកៗពីគ្នាអំពីវិធីដែលផែនការនានារួមទាំងការបម្រុះស្ពាន ចាប់ យកខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងបានសម្រេច ដោយរបៀបណានៅក្នុង ពេលប្រជុំទៀងទាត់នៅឃុំស្ពៅ[93]។ ឧទាហរណ៍ទាំងអស់នេះមិនគ្រាន់តែបានផ្ដល់ទម្ងន់បន្ថែមលើ ការរៀបរាប់របស់សាក្សី SCW-5 អំពីការបង្កើតឃ្លាំងអាវុធនៅក្នុងព្រៃនៅដើមឆ្នាំ ១៩៧៥ ប៉ុណ្ណោះទេ ប៉ុន្តែក៏ថែមទាំងបានចោទប្រកាន់អំពីការបង្កើត និងការចូលរួមនៅក្នុងចលនាខ្មែរស ផងដែរ[94]។ ឧទាហរណ៍ទាំងនេះបង្ហាញថា វត្តមានសាក្សីទាំង ៥ រូប នៅក្នុងសវនាលើបណ្ដឹង សាទុក្ខមានសារៈសំខាន់ខ្លាំងណាស់សម្រាប់មេធាវីការពារក្ដី។

57. ចំណុចចុងក្រោយ សាក្សីទាំងបួនរូបនៅក្នុង [redacted] និងសាក្សីចំនួន ៣ រូប ដែលត្រូវ បានពិពណ៌នានៅក្នុងសៀវភៅចំណងជើងថា *នៅពីក្រោយវាលពិឃាត* ជួយលាតត្រដាងនូវហេតុ ការណ៍បិទបាំងនៅក្នុងភូមិភាគពាយ័ព្យរហូតមកដល់ពេលនេះ។ សាក្សីចំនួន ៤ រូបនៅក្នុង [redacted] បានពន្យល់លម្អិតថាតើកម្មាភិបាលភូមិភាគនិរតីបានមកដល់ភូមិភាគពាយ័ព្យដោយ របៀបណា ហើយថាតើពួកគេបានចាប់ផ្ដើមចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យនាពេលក្រោយ

---

[89] *សូមមើល* កថាខណ្ឌ ១៦ ខាងលើ។

[90] *សូមមើល* កថាខណ្ឌ ២៨ ខាងលើ។

[91] *សូមមើល* កថាខណ្ឌ ២៦ ខាងលើ។

[92] *សូមមើល* កថាខណ្ឌ ៤៣ និង ៤៤ ខាងលើ។

[93] *សូមមើល* កថាខណ្ឌ ៤៤ និង ៤៦ ខាងលើ។

[94] *សូមមើល ឧ.* ឯកសារ E319.1.27 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី SCW-5 លើកទីមួយ ទំព័រ ១១ (ត្រង់ ឆ.៣៥) និងទំព័រ ១២ (ត្រង់ ឆ.៣៨)។

មកដោយរបៀបណាផងដែរ[95]។ លើសពីនេះ សាក្សីក្នុង[redacted]នីមួយៗ ពន្យល់ស៊ីជម្រៅអំពីរចនាសម្ព័ន្ធភូមិភាគពាយ័ព្យ បង្ហាញអត្តសញ្ញាណសមាជិកថ្នាក់ដឹកនាំរបស់ភូមិភាគនេះ និងរៀបរាប់លម្អិតអំពីជោគវាសនានៃមេដឹកនាំផ្សេងទៀត[96]។ ចំណែកសាក្សីចំនួន ៣ រូបនៅក្នុងសៀវភៅចំណងជើងថា *នៅខាងក្រោយវាលពិឃាត* បង្ហាញថាតើការបះបោរ និង/ឬ ការក្បត់ជាតិនៅក្នុងភូមិភាគពាយ័ព្យត្រូវបាន (និងទំនងជាត្រូវបាន) ប្រតិបត្តិការយ៉ាងដូចម្តេច។ ព័ត៌មានទាំងអស់នេះផ្តល់នូវបរិបទចាំបាច់មិនត្រឹមតែសម្រាប់ផ្ទៀងផ្ទាត់សក្ខីកម្មផ្ទាល់របស់ SCW-5 ប៉ុណ្ណោះនោះទេ ប៉ុន្តែសម្រាប់បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីទាំងមូលផងដែរ។

### *(ii) កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី SCW-5 ទីពីរ និងឧបសម្ព័ន្ធ*

58. មេធាវីការពារក្តីសូមដាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី SCW-5 ទីពីរ និងឧបសម្ព័ន្ធដើម្បីឆ្លើយតបទៅនឹងកាលវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលកោះហៅសាក្សី SCW-5 ឱ្យមកផ្តល់សក្ខីកម្មនៅក្នុងបណ្តឹងសាទុក្ខ។ មេធាវីការពារក្តីយល់ឃើញថា កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទីពីរ និងឧបសម្ព័ន្ធជួយឱ្យអង្គជំនុំជម្រះយល់ពេញលេញលើព័ត៌មាននៅក្នុងសំណុំរឿងទាក់ទងនឹងសាក្សី SCW-5 និងផ្តល់ជាព័ត៌មានបន្ថែមដែលអាចជួយអង្គជំនុំជម្រះក្នុងការលាតត្រដាងការពិត។ ជាពិសេស នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយទីពីររបស់សាក្សី SCW-5 ផ្តល់ព័ត៌មានទាក់ទងនឹងលេខាផ្ទាល់របស់ រញ់ ញឹម និងទាក់ទងនឹងសំណៅរូបថតសល់ពីសម័យកម្ពុជាប្រជាធិបតេយ្យ រួមទាំង រូបថតមួយសន្លឹកដែលអាចជារូបថត រស់ ញឹម ផងដែរ[97] ហើយរូបថតនេះពុំមាននៅក្នុងសំណុំរឿង ០០២ ទាល់តែសោះ។

## ឃ. ភស្តុតាងបន្ថែមរបស់សាក្សីចំនួន ៤ រូបនៅក្នុងសំណុំរឿង ០០៤ គួរតែទទួលយកអនុលោមតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង

59. វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់លាស់អំពីលទ្ធភាពបើកឱ្យដាក់សំណើសុំភស្តុតាងបន្ថែមនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលដរាបណាភស្តុតាងបែបនេះ "រកពុំបាននៅក្នុងពេលជំនុំជម្រះ"។ មេធាវីការពារក្តីពុំបានដឹងអំពីសាក្សីទី ១, ២, ៣, និង ៤ នៅមុនពេលកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ពួកគេត្រូវបានដាក់បង្ហាញ។ ពួកគេពុំដែលធ្លាប់បានផ្តល់

---

[95] *សូមមើល* កថាខណ្ឌ ២០, ២៧, ៣៣, និង ៤១ ខាងលើ។

[96] *សូមមើល* កថាខណ្ឌ ២១-២២, ២៥, ៣០, ៣៤-៣៦ និង ៤០ ខាងលើ។

[97] *សូមមើល* កថាខណ្ឌ ៤៨ ខាងលើ។

សក្ខីកម្មនៅក្នុងសំណុំរឿង ០០២ នោះទេ [redacted] ។ [redacted] ។ ហេតុដូច្នេះ ភ័ស្តុតាងរបស់ពួកគេអាចត្រូវបានចាត់ទុកយ៉ាងច្បាស់ថាជាភ័ស្តុតាង ដែលពុំអាចរកបាននៅក្នុងពេលជំនុំជម្រះយោងតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។

**ង. ភ័ស្តុតាងបន្ថែមរបស់សាក្សីទាំងបួននៅក្នុងសំណុំរឿង ០០៤ សាក្សីចំនួនបីរូបដែលកិច្ចសម្ភាសន៍របស់ពួកគេបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅចំណងជើងថានៅពីក្រោយវាលពិឃាត និង SCW-5 គួរទទួលយកអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង**

60. វិធាន ១០៤(១) ក៏បានផ្តល់អំណាចឲ្យអង្គជំនុំជម្រះតុលាការកំពូល "ស្វែងរកភ័ស្តុតាងថ្មី" "នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ ដោយត្រូវពិចារណាទៅលើកាលៈទេសៈជាក់លាក់នៃរឿងក្តី"[98]។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា ទាក់ទងនឹងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់សាលដីកា *Lubanga* នាពេលថ្មីៗនេះ ហើយបានបញ្ជាក់ថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC នៅក្នុងរឿងក្តីនេះ "បានរកឃើញថា ខ្លួនមានឆន្ទានុសិទ្ធិក្នុងការទទួលយកភ័ស្តុតាងលើបណ្តឹងសាទុក្ខ បើទោះបីជាការយល់ឃើញនេះអវិជ្ជមានចំពោះលក្ខណៈវិនិច្ឆ័យមួយ ឬ ច្រើនដែលកំណត់ពីភាពអាចទទួលយកបាននូវភ័ស្តុតាងលើបណ្តឹងសាទុក្ខក៏ដោយ"[99]។

61. មេធាវីការពារក្តីសូមសន្និដ្ឋានថា ទោះបីជាសក្ខីកម្មទាំងមូល ឬ ផ្នែកខ្លះនៃសាក្សីទី ១-៤ ត្រូវបានចាត់ទុកថាពុំបានបំពេញលក្ខខណ្ឌនៃវិធាន ១០៨(៧) និងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏សក្ខីកម្មទាំងនេះគួរទទួលយកអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងដើម្បីជាប្រយោជន៍នៃយុត្តិធម៌។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីស្នើសុំឲ្យកោះហៅសាក្សីចំនួន ៣ រូប ដែលកិច្ចសម្ភាសន៍របស់ពួកគេត្រូវបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅចំណងជើងថា *នៅពីក្រោយវាលពិឃាត* ហើយស្នើសុំឲ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយទីពីរ និងឧបសម្ព័ន្ធរបស់សាក្សី

---

[98] ឯកសារ F2/5 សេចក្តីសម្រេចលើកទីមួយលើសាក្សី កថាខណ្ឌ ១៧។

[99] ឯកសារ F2/5 សេចក្តីសម្រេចលើកទីមួយលើសាក្សី លេខយោងជើងទំព័រ ១៧។

SCW-5 អនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង និងដើម្បីផលប្រយោជន៍នៃយុត្តិធម៌។

62. ទាក់ទងនឹងសាក្សីទី ១-៤ [redacted] ដោយសារតែលក្ខខណ្ឌនានាដែលមេធាវីការពារក្តីបានប្រឈមលើការងារនេះ [redacted] មេធាវីការពារក្តីសូមសន្និដ្ឋានថា ខ្លួនបានប្រឹងប្រែងដោយយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវក្នុងការ [redacted] ហើយសូមដាក់សាក្សីទី ១ ដល់ ៤ ជូនអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងពេលនេះតែម្តង។ មេធាវីការពារក្តីកត់សម្គាល់បន្ថែមទៀតថា កំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះត្រូវបានដាក់មួយផ្នែកធំដើម្បីបញ្ជាក់ និងផ្ទៀងផ្ទាត់ជាមួយនឹងសក្ខីកម្មរបស់ សាក្សីSCW-5។ ហេតុដូច្នេះ ការដាក់កំណត់ហេតុទាំងនេះគឺជាការឆ្លើយតបទៅនឹងដីកាកំណត់កាលវិភាគនាពេលថ្មីៗកោះហៅសាក្សី SCW-5 មកធ្វើជាសាក្សី។

63. ទាក់ទងនឹងសាក្សី 2-TCW-959, 2-TCW-960 និង 2-TCW-961 មេធាវីការពារក្តីកត់សម្គាល់ថា មេធាវីការពារក្តីពុំស្នើសុំសក្ខីកម្មរបស់ពួកគេក្នុងដំណាក់កាលបណ្តឹងសាទុក្ខនេះទេដោយសារខ្លួនកំពុងរង់ចាំការវិវឌ្ឍបន្ថែមទាក់ទងនឹងសំណើរបស់ខ្លួនសុំភស្តុតាងបន្ថែមពី Rob Lemkin និង ថេត សម្បត្តិ និងសុំកោះហៅបុគ្គលពីររូបនេះមកផ្តល់សក្ខីកម្ម។ ជាពិសេស មេធាវីការពារក្តីសង្ឃឹមថា សាក្សីពីររូបនេះនឹងយល់ស្របផ្តល់ខ្សែរូបភាពដែលពុំទាន់ផ្សាយទាក់ទងនឹងអ្នកដែលត្រូវបានសម្ភាសន៍ទាំងបួនរូបសម្រាប់ខ្សែភាពយន្តរបស់ពួកគេចំណងជើងថា *សត្រូវប្រជាជន/មួយថ្ងៃនៅទួលពោធិ៍ជ្រៃ/ភាពសង្ស័យ* ដែលជាហេតុអាចនឹងពុំចាំបាច់ស្នើសុំសាក្សីបន្ថែមទាំងនេះនោះឡើយ។ សំណើបច្ចុប្បន្នសុំកោះហៅសាក្សី 2-TCW-959, 2-TCW-960 និង 2-TCW-961ឱ្យមកផ្តល់សក្ខីកម្មគឺជាផលវិបាកផ្ទាល់ចេញពីរបាយការណ៍របស់ WESU អំពីកិច្ចពិភាក្សារបស់ខ្លួនជាមួយនឹង ថេត សម្បត្តិ និងកិច្ចសម្ភាសន៍ Rob Lemkin ដោយអង្គជំនុំជម្រះ ដូចដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន[100]។ ថេត សម្បត្តិ ពុំព្រមផ្តល់ខ្សែរូបភាពបន្ថែមពីខ្សែវីដេអូរបស់គាត់ ឬ ប្រតិចារឹកនៃខ្សែវីដេអូទាំងនេះនោះទេ[101] ដោយឈរលើមូលដ្ឋានថា អ្នក

[100] **F2/4/3/3**, សេចក្តីសម្រេចអន្តរកាលរបស់អជតក, ទំព័រ

[101] ឯកសារ **F2/4/3/2** “របាយការណ៍ឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល F/2/4/3” ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ ERN 01098357 កថាខណ្ឌ ១៧។

ផ្តល់កិច្ចសម្ភាសន៍ទាំងបួនរូបនោះ "ពុំយល់ព្រមឱ្យប្រើប្រាស់សម្ភារៈព័ត៌មានរបស់ពួកគេទោះក្នុងទម្រង់ ឬ ក្នុងគោលបំណងណាក៏ដោយ" ហើយការផ្សាយចេញនឹង "បង្កគ្រោះថ្នាក់" ដល់ពួកគេ ហើយវាគឺជា "ការរំលោភលើសិទ្ធិរបស់ពួកគេផងដែរ"។ Rob Lemkin បានផ្តល់យោបល់ថា អង្គជំនុំជម្រះចាំបាច់ត្រូវសុំការអនុញ្ញាតពី ថេត សម្បត្តិ ឱ្យប្រគល់ខ្សែរូបភាពវីដេអូ ឬ សម្ភារៈព័ត៌មានណាមួយ[102]។ ករណីនេះនឹងពុំអាចទៅរួចទាល់តែសោះអាចឱ្យព័ត៌មាននៅក្នុងខ្សែរូបភាពវីដេអូ ឬ សម្ភារៈព័ត៌មានបន្ថែមនេះមានលទ្ធភាពដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

64. ដោយសារតែពុំមានភស្តុតាងសំខាន់នេះរួមជាមួយនឹងសក្ខីកម្មដែលសាក្សី 2-TCW-959, 2-TCW-960 និង 2-TCW-961 ទំនងអាចនឹងផ្តល់ឱ្យនេះហើយទើបបង្វែរបុគ្គលទាំងបីរូបនេះក្លាយជាសាក្សីសំខាន់របស់មេធាវីការពារក្តីសម្រាប់បណ្តឹងឧទ្ធរណ៍។ ការផ្តល់សក្ខីកម្មរបស់បុគ្គលទាំងបួនដែលបានរៀបរាប់នៅក្នុងកិច្ចសម្ភាសរបស់អង្គជំនុំជម្រះជាមួយ Lemkin, 2-TCW-959, 2-TCW-960 និង 2-TCW-961 ទំនងជាសកម្មភាពវិទ្ធង្សាណានៅភូមិភាគពាយ័ព្យ ដែលដឹកនាំដោយ រស់ ញឹម។ សាក្សីទាំងបីរូបនេះត្រូវបានហៅឈ្មោះចំៗ ហើយប្រវត្តិរូប និងបទពិសោធន៍ដែលពួកគេបានឆ្លងកាត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានពិភាក្សាជាចំហនៅក្នុងសៀវភៅចំណងជើងថា *នៅពីក្រោយវាលពិឃាត*។ នេះគឺជាសៀវភៅដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០១០ ត្រូវបានចែកចាយយ៉ាងទូលំទូលាយ ត្រូវបានគេស្គាល់ មាននៅក្នុងសំណុំរឿង ហើយបច្ចុប្បន្នមានលក់នៅបណ្ណាគារម៉ូញូមែនក្នុងប្រទេសកម្ពុជាទៀតផង។ ការព្រួយបារម្ភរបស់ ថេត សម្បត្តិ រួមជាមួយនឹងការព្រួយបារម្ភអំពីលទ្ធភាពអាចប្រើប្រាស់ និងភាពគ្រោះថ្នាក់នៃកិច្ចសម្ភាសន៍ជាមួយនឹងសាក្សីទាំងបួនរូប ដែលលើកឡើងដោយ Rob Lemkin ហើយដែលបានពិភាក្សានៅកថាខណ្ឌ១១ខាងលើ គឺពុំមានទេសម្រាប់សាក្សី 2-TCW-959, 2-TCW-960 និង 2-TCW-961។ កិច្ចសម្ភាសន៍របស់បុគ្គលទាំងបីនាក់នេះ គឺត្រូវបានប្រើប្រាស់ក្នុងបរិបទជាជាងភាពយន្តឯកសារ ដោយសន្មត់ថា អ្នកដែលផ្តល់កិច្ចសម្ភាសន៍នេះបានអនុញ្ញាតឱ្យ សម្បត្តិ ប្រើប្រាស់កិច្ចសម្ភាសន៍របស់ខ្លួនរួចហើយ។ ជាងនេះទៅទៀតនោះ សម្បត្តិ បានបោះពុម្ពនូវរឿងរ៉ាវក្នុងកិច្ចសម្ភាសន៍ទាំងនេះនៅក្នុងសៀវភៅរបស់គាត់ ហើយគ្មានវិធានការការពារណាមួយមានឡើយសម្រាប់ សម្បត្តិ គ្រួសាររបស់គាត់ ឬក៏អតីតអ្នកបម្រើការរបស់គាត់ទាក់ទងនឹងបទសម្ភាសន៍របស់គាត់នោះទេ។

---

[102] ឯកសារ **F2/4/3/1** "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី Robert T.F. Lemkin" ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ ERN 01097188។

65. លើសពីនេះ ទាក់ទងនឹងភស្តុតាងដែលផ្តល់ជូនដោយសាក្សីទី ១-៤ និង 2-TCW-959, 2-TCW-960 និង 2-TCW-961 មេធាវីការពារក្តីសូមគូសបញ្ជាក់ឡើងវិញថា សក្ខីកម្មរបស់ពួកគេអាចបង្កើតជាវិធីការពារក្តីសំខាន់នៅក្នុងបណ្តឹងសាទុក្ខ ជាពិសេស ត្រង់ថា "មជ្ឈិមបក្ស" ក្នុងក្រុងភ្នំពេញអនុវត្តការគ្រប់គ្រងមានប្រសិទ្ធភាពបន្តិចបន្តួចប៉ុណ្ណោះ ហើយ "មេដឹកនាំភូមិភាគ" ដូចជា សោ ភឹម និង រស់ ញឹម បានអនុវត្តសិទ្ធិអំណាចឯករាជ្យធំធេង ហើយពួកគេបានប្រើប្រាស់សិទ្ធិអំណាចនេះតាំងពីថ្ងៃដំបូងៗ ក្រោយពេលរំដោះនាថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដើម្បីបង្កើតការបះបោរ និង/ការក្បត់ជាតិប្រឆាំងនឹងបក្ស និងរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជាប្រជាធិបតេយ្យ ដែលខ្លួនធ្វើឡើងដោយមានការគាំទ្ររឹងមាំពីវៀតណាម ដែលគាំទ្រដោយសហភាពសូវៀត និងដោយទំនងជាមានការពាក់ព័ន្ធនឹងសម្ព័ន្ធភាពរវាង សោ ភឹម រស់ ញឹម និងផ្សេងទៀតផងដែរ។ ហេតុដូច្នេះ ការទទួលយកភស្តុតាងរបស់ពួកគេពិតជាមានសារសំខាន់ណាស់។

66. ពាក់ព័ន្ធនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី SCW-5 ទីពីរ និងឧបសម្ព័ន្ធនោះ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការទទួលយកសម្ភារៈទាំងនេះគឺដើម្បីផលប្រយោជន៍នៃយុត្តិធម៌ដោយសារវាជួយឲ្យអង្គជំនុំជម្រះតុលាការកំពូលយល់ពេញលេញ អំពីវិសាលភាពនៃសក្ខីកម្មរបស់សាក្សី SCW-5 ដែលនឹងផ្តល់ជូននៅមុនពេលគាត់បង្ហាញខ្លួនមកផ្តល់សក្ខីកម្ម។

## V. សំណើសុំ

67. អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមស្នើសុំឲ្យ៖

(ក) ទទួលយកភស្តុតាងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទី ១, ២, ៣, ៤ និង SCW-5 ដែលបានដាក់ភ្ជាប់ជាមួយនឹងសំណើសុំនេះ និង

(ខ) កោះហៅសាក្សីទី ១, ២, 2-TCW-959, 2-TCW-960 និង 2-TCW-961 ឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។

**សហមេធាវីការពារក្តី នួន ជា**

**សុន អរុណ** **Victor Koppe**